*The Plan*

Copyright © 2012 by The Gospel Coalition

Published by Crossway
a publishing ministry of Good News Publishers
Wheaton, Illinois 60187, U.S.A.

This edition published by arrangement with Crossway.
All rights reserved.

This project was accomplished in partnership with The Gospel Coalition International Outreach.

# ផែនការរបស់ព្រះជាម្ចាស់

លោក ខូលីន ស ស្មីត Colin S. Smith

**មាតិកា**

ព្រះមានព្រះបន្ទូលប្រកាសការសន្យាមួយៈ រឿងក្នុងព្រះគម្ពីរសញ្ញាចាស់ ........ 3

ព្រះគ្រីស្ទបំពេញសម្រេចសេចក្ដីសន្យាៈ រឿងក្នុងកណ្ដូដំណឹងល្អ ........ 9

ពួកជំនុំប្រកាសសេចក្ដីសន្យាៈ រឿងនៅក្នុងកណ្ឌកិច្ចការ ........ 15

ព្រះវិញ្ញាណបរិសុទ្ធប្រទានសេចក្ដីសន្យាៈ រឿងក្នុងកណ្ឌសំបុត្រក្នុងព្រះគម្ពីរសញ្ញាថ្មី ........ 16

កំណត់ ........ 22

អ្នកខ្លះគិតថា ព្រះបានមានផែនការដ៏ល្អអស្ចារ្យសម្រាប់ពិភពលោក ប៉ុន្តែព្រះបានបង្កើតទាំងអស់ដោយមិនជ្រាបថា មនុស្សនឹងបះបោរនឹងព្រះអង្គហើយការបះបោររបស់មនុស្សបានបំផ្លាញផែនការរបស់ព្រះ ដូច្នេះព្រះត្រូវបង្កើតផែនការថ្មី ដើម្បីដោះស្រាយបញ្ហានោះ។ នេះមិនមែនគឺជាអ្វីដែលព្រះគម្ពីរបង្រៀននោះទេ។

ព្រះមិនដូចជារដ្ឋាភិបាលដែលឆ្លើយតបចំពោះស្ថានភាពដែលមិនបានមើលឃើញជាមុន និងផ្លាស់ប្ដូរនយោបាយ ពីព្រោះមានព្រឹត្តិការណ៍កើតឡើងដែលគេមិនបានដឹងជាមុននោះទេ។ ទ្រង់មិនដូចជាអ្នកវិទ្យាសាស្ត្រដែលពិសោធន៍មើល ការងារអ្វី ឬសហគ្រិនពាណិជ្ជកម្មដែលជោគជ័យដោយសារការស្វែងរកគំនិតថ្មីៗឆ្លើយតបចំពោះសេចក្ដីត្រូវការដែលលេច ឡើងផ្សេងៗនោះទេ។

ការនាំពួកមនុស្សមានបាបទៅឯជីវិតអស់កល្បជានិច្ចតាមរយៈព្រះគ្រីស្ទតែងតែជាផែនការរបស់ព្រះ។ ព្រះជាម្ចាស់បាន សន្យានឹងប្រទានជីវិតអស់កល្បជានិច្ច «មុនអស់ទាំងកល្បតែនៅពេលកំណត់នោះទើបបានសំដែងចេញឱ្យស្គាល់ព្រះ បន្ទូលទ្រង់» (ទីតុស ១:២-៣)។[1] មុនពេលទ្រង់បានបង្កើតពិភពលោក ព្រះបានទតឃើញអំណរដែលនឹងមកពីការប្រោស លោះពួកមនុស្សមានបាបជាច្រើនចេញពីទ្វីបនិមួយៗនៃពិភពលោក និងគ្រប់ទាំងជំនាន់និមួយៗពេញក្នុងប្រវត្តិសាស្ត្រ។ ដោយដឹងអំពីអ្វីដែលព្រះអង្គត្រូវធ្វើ នោះទ្រង់បានកំណត់ព្រះទ័យធ្វើការនេះ។

នេះគឺជាមូលហេតុដែលព្រះគម្ពីរពិពណ៌នាអំពីព្រះគ្រីស្ទថា «កូនចៀមត្រូវគេសម្លាប់តាំងពីកំណើតលោកិយមក» (វិវរណៈ ១៣:៨)។ ការសុគតរបស់ព្រះគ្រីស្ទនៅលើឈើឆ្កាងមិនមែនជាគំនិតថ្មីរបស់ព្រះដើម្បីឆ្លើយតបចំពោះជ័យជំនះ របស់សាតាំងនៅក្នុងសួនច្បារអេដែន ឬនៅពេលមនុស្សពិតជាមិនអាចស្ដាប់បង្គាប់តាមក្រឹត្យវិន័យទាំងដប់ប្រការនោះទេ។ ការប្រោសលោះពួកមនុស្សមានបាបចេញពីជាតិសាសន៍ទាំងអស់តាមរយៈព្រះយេស៊ូវគ្រីស្ទគឺជាផែនការរបស់ព្រះតាំងពី មុនដំបូង។

ផែនការរបស់ព្រះខុសពីផែនការរបស់យើង។ នៅពេលយើងនិយាយថា «ខ្ញុំនឹងញ៉ាំអាហារពេលព្រឹកជាមួយអ្នកនៅថ្ងៃ អង្គារក្រោយ» ខ្ញុំមានន័យថា «សន្មត់ថាខ្ញុំនៅរស់ ខ្ញុំមានមធ្យោបាយធ្វើដំណើរ ខ្ញុំមិនមានការបន្ទាន់ផ្សេងទៀត ហើយថា ភោជនីយដ្ឋានបើកនិងមានលក់អាហារពេលព្រឹក នោះខ្ញុំនឹងជួបអ្នកនៅថ្ងៃអង្គារ»។

ផែនការរបស់យើងអាស្រ័យលើរបៀបដែលព្រឹត្តិការណ៍មានដំណើរការ ហើយថាយើងមានសមត្ថភាពបំពេញ សម្រេចវាដែរឬយ៉ាងណា។ មានការជាច្រើនក្នុងជីវិតដែលកើតឡើងលើសពីការគ្រប់គ្រងរបស់យើង។

ប៉ុន្តែទ្រង់មានអធិបតីភាព។ទ្រង់បំពេញសម្រេចផែនការរបស់ទ្រង់នៅក្នុងពេលវេលានិងដោយអំណាចរបស់ទ្រង់ផ្ទាល់ ហើយគ្មាននរណាម្នាក់អាចបញ្ឈប់ឬរារាំងទ្រង់បានឡើយ។ ព្រះជ្រាបយ៉ាងច្បាស់លាស់អំពីគ្រប់ការទាំងអស់ដែលទ្រង់កំពុងធ្វើក្នុងគ្រប់ចំនុចក្នុងប្រវិត្តិសាស្រ្តក្នុងជាតិសាសន៍និមួយៗក្នុងពិភពលោក ហើយតាមរយៈព្រឹត្តិការណ៏និមួយៗក្នុងជីវិតរបស់អ្នក។

នេះគួរតែកំសាន្តចិត្តយើង។ គ្មានអ្វីដែលអ្នកធ្លាប់បានធ្វើ ឲ្យព្រះភ្ញាក់ផ្អើលនោះទេ។ គ្មានអ្វីដែលបានកើតឡើងចំពោះអ្នកដែលព្រះមិនដឹងជាមុននោះឡើយ។ គ្មានអ្វីដែលអ្នកធ្វើ ហើយគ្មានអ្វីកើតឡើងចំពោះអ្នកដែលអាចរារាំងព្រះពីការបំពេញសម្រេចផែនការរបស់ទ្រង់ ឬពន្យឺតទ្រង់នោះឡើយ។ សេចក្តីពិតដែលថា ទ្រង់មានអធិបតីយភាព មានន័យយ៉ាងនេះ។

ព្រះដឹងយ៉ាងច្បាស់អំពីអ្វីដែលទ្រង់កំពុងធ្វើ។ អ្នកអាចមានទំនុកចិត្តក្នុងការដឹងថា ព្រឹត្តិការណ៏ផ្សេងៗក្នុងជីវិតរបស់អ្នកមិនលើសពីការគ្រប់គ្រងរបស់ព្រះអង្គ ឬបានកើតឡើងដោយចៃដន្យនោះទេ ប៉ុន្តែស្ថិតក្នុងព្រះហស្តរបស់ព្រះដែលមានផែនការដែលព្រះជាម្ចាស់បានគ្រោងទុកដោយសេចក្តីស្រឡាញ់សម្រាប់អ្នក។ ពួកគ្រីស្ទបរិស័ទមានអំណរក្នុងការដឹងថាផែនការរបស់ព្រះនឹងនាំទៅកាន់ការបង្ហាញសិរីល្អដ៏ធំបំផុតរបស់ទ្រង់ ហើយនិងអំណរដ៏ធំបំផុតសម្រាប់ប្រជារាស្រ្តរបស់ទ្រង់។

ខ្ញុំអញ្ជើញអ្នកឲ្យចូលរួមជាមួយខ្ញុំក្នុងការធ្វើដំណើរកាត់ខ្សែរឿងរបស់ព្រះគម្ពីរដែលព្រះបើកសំដែងអំពីភាពរុងរឿងនៃគោលបំណងដ៏អស្ចារ្យរបស់ទ្រង់ដែលគ្របដណ្តប់តាំងពីអតីតកាលអស់កល្បជានិច្ចគ្រប់ជំនាន់ប្រវត្តិសាស្រ្តរបស់មនុស្សទៅដល់អនាគតអស់កល្បជានិច្ច។

យើងចាប់ផ្តើមនៅក្នុងព្រះគម្ពីរសញ្ញាចាស់ដែលព្រះបើកសំដែងការបង្កើតផែនការរបស់ទ្រង់។ បន្ទាប់មក ក្នុងកណ្ឌដំណឹងល្អ យើងមើលលើរបៀបព្រះយេស៊ូវគ្រីស្ទសម្រេចបានគ្រប់ការដែលផែនការត្រូវការសម្រេចបាន។ នៅចុងបញ្ចប់យើងមើលលើសំបុត្រផ្សេងៗក្នុងព្រះគម្ពីរសញ្ញាថ្មី ហើយរីករាយ ពីព្រោះព្រះវិញ្ញាណបរិសុទ្ធប្រទានគ្រប់ទាំងអស់ដែលព្រះបានសន្យា ហើយគ្រប់ទាំងអស់ដែលព្រះគ្រីស្ទសម្រេចបានក្នុងជីវិតប្រជារាស្រ្តទាំងអស់របស់ព្រះ។

## *ព្រះមានព្រះបន្ទូលប្រកាសការសន្យាមួយ: រឿងក្នុងព្រះគម្ពីរសញ្ញាចាស់*

ព្រះបញ្ចេញផែនការរបស់ទ្រង់តាមរយៈសកម្មភាពប្រាំពីរដែលពេញដោយសេចក្តីសន្យាសម្រាប់ប្រជារាស្រ្តទាំងអស់របស់ទ្រង់។

### ការបង្ករបង្កើត

«កាលដើមដំបូងឡើយ ព្រះបានបង្កើតផ្ទៃមេឃនិងផែនដី»(លោកុប្បត្តិ ១:១)។ មុនពេលដែលព្រះជាម្ចាស់បង្កើតរបស់សព្វសារពើរមិនមានអ្វីនោះឡើយ លើកលែងតែព្រះ។ ព្រះបានបង្កើតរបស់សព្វសារពើ ហើយរបស់សព្វសារពើជារបស់ផងទ្រង់។ «ផែនដីនិងសារពើនៅផែនដីជារបស់ផងព្រះយេហូវ៉ា ព្រមទាំងលោកិយ និងបណ្តាអ្នកដែលនៅលើលោកិយផង» (ទំនុកដំកើង ២៤:១)។

ចូរមើលអ្វីដែលព្រះបានបង្កើត។ ចូរមើលទៅមេឃ វាប្រកាសអំពីការងាររបស់ព្រះហស្តព្រះ។ ចូរស្តាប់ពួកសត្វបក្សីពួកវាធ្វើបន្ទាល់ដោយការយកព្រះទ័យទុកដាក់ដ៏ទន់ភ្លន់របស់ព្រះ។ គ្រប់ទាំងគ្រាប់ហិមៈធ្វើបន្ទាល់ពីព្រះចេស្តាររបស់ទ្រង់។ ពេលថ្ងៃរះម្តងៗនិយាយអំពីសេចក្តីស្មោះត្រង់របស់ទ្រង់។ «ផ្ទៃមេឃសំដែងពីសិរីល្អនៃព្រះ ហើយលំហរអាកាសក៏បង្ហាញការដែលព្រះហស្តទ្រង់ធ្វើ......ឯពាក្យសំដី ឬភាសានោះគ្មានឮឡើយ» (ទំនុកដំកើង ១៩:១-៣)។

របស់សព្វសារពើរដែលព្រះអង្គបង្កើតឆ្លុះឲ្យឃើញសិរីល្អរបស់ព្រះ ប៉ុន្តែព្រះបានធ្វើការពិសេសមួយនៅពេលទ្រង់បានបង្កើតមនុស្សប្រុសស្រីដើមដំបូង។ យើងដឹងការនេះដោយព្រោះព្រះបានមានបន្ទូលថា

«ចូរយើងធ្វើមនុស្សឱ្យដូចជារូបយើង ឱ្យមានភាពដូចយើង ហើយឱ្យមានអំណាចលើត្រីសមុទ្រ សត្វហើរលើអាកាស និងសត្វជើង៤ ដែលនៅលើផែនដីទាំងមូល ព្រមទាំង សត្វលូនវារ ដែលវារនៅផែនដីផង»(លោកុប្បត្តិ ១:២៦)។

ព្រះបានបង្កើតមនុស្សប្រុសមនុស្សស្រីនៅក្នុងរូបភាពនៃទ្រង់។ នេះជាមូលហេតុដែលយើងខុសពីតិណជាតិ សត្វពាហនៈ មច្ឆា និងបក្សី។ ពួកវាត្រូវបានបង្កើតដោយព្រះ ប៉ុន្តែមានតែមនុស្សទេដែលត្រូវបានបង្កើតឲ្យដូចជាព្រះ។ ការនេះផ្តល់ឲ្យជីវិតរបស់មនុស្សនូវតម្លៃពិសេសដាច់ដោយឡែក។

ព្រះបានជ្រើសរើសនាំអ្នកឲ្យមានជីវិត។ ទ្រង់មិនដែលបង្កើតនរណាម្នាក់ឲ្យដូចជាអ្នកពីមុនមកទេ ហើយទ្រង់នឹងមិនដែលបង្កើតនរណាម្នាក់ឲ្យដូចអ្នកម្តងទៀតនោះដែរ។ អ្នកមិនមែនកើតមកដោយចៃដន្យនោះឡើយ។ អ្នកត្រូវបានបង្កើតដោយព្រះ ហើយអ្នកត្រូវបានបង្កើតសម្រាប់ព្រះ។ គោលបំណងធំបំផុតនៃជីវិតរបស់អ្នកគឺថា អ្នកគួរតែឆ្លុះឲ្យគេឃើញសិរីរុងរឿងរបស់ព្រះយេស៊ូគ្រីស្ទ។ អ្នកត្រូវបានបង្កើតដើម្បីថ្វាយសិរីល្អដល់ព្រះ ហើយដើម្បីរីករាយជាមួយនឹងទ្រង់អស់កល្បជានិច្ច។

តើព្រះអង្គបានសន្យាអ្វី? ព្រះបានសន្យានឹងប្រទានជិវិតដល់មនុស្សដែលឆ្លុះឲ្យឃើញសិរីរុងរឿងរបស់ទ្រង់។

ព្រះគម្ពីរមិនដែលពន្យល់យ៉ាងច្បាស់លាស់អំពីដើមកំណើតរបស់ការអាក្រក់នោះទេ តែវាប្រាប់យើងថា ព្រះបានដាក់មនុស្សប្រុសនិងមនុស្សស្រីនៅក្នុងសួនច្បារមួយដែលមានគ្រប់យ៉ាងល្អ។ អាហាររបស់ពួកគេមាននៅលើដើមឈើ គេពេញចិត្តនឹងការងាររបស់គេសហភាពនិងអំណរក្នុង អាពាហ៍ពិពាហ៍របស់ពួកគេបានពេញលេញ ហើយពួកគេបានរស់នៅមានទំនាក់ទំនងជាមួយព្រះដែលបានលេចមកឯពួកគេ ហើយដើរជាមួយពួកគេនៅក្នុងសួនច្បារ។

មានដើមឈើមួយដើមក្នុងសួនច្បារដែលហៅថា «ដើមដឹងខុសត្រូវ» ហើយព្រះបានប្រាប់មនុស្សប្រុសនិងមនុស្សស្រីមិនឲ្យបរិភោគផ្លែពីដើមនោះទេ (លោកុប្បត្តិ ២:១៧)។ ដោយសារតែគ្រប់យ៉ាងដែលពួកគេបានដឹងគឺល្អ នោះការមួយដែលពួកគេអាចទទួលបានពីការមិនស្តាប់បង្គាប់ព្រះគឺជាការដឹងអំពីការអាក្រក់។ សត្វពស់បានមកល្បួងពួកគេដោយការដឹងអំពីការអាក្រក់ហើយនោះជាអ្វីដែលពួកគេបានជ្រើសរើស។ ក្នុងសកម្មភាពមិនស្តាប់បង្គាប់ព្រះ ពួកគេបានទទួលការដឹងអំពីការអាក្រក់ ហើយយើងទាំងអស់គ្នាក៏ជាប់ក្នុងវាតាំងពីពេលនោះមក។ ប៉ុន្តែព្រះបានប្រកាសសេចក្តីសន្យាមួយផ្សេងទៀត។

## សេចក្តីវិនាស

ព្រះបានមានបន្ទូលទៅសត្វពស់ដែលប្រកាសបណ្តាសា (នៅក្នុងភាសាហេប្រើរ (ហើយភាសាអង់គ្លេស) លោកុប្បត្តិ ៣:១៤ មានពាក្យ«បណ្តាសា» ប៉ុន្តែព្រះគម្ពីរខ្មែរខ្វះពាក្យនេះ)។ ដាក់បណ្តាសារមានន័យថាកំណត់ឲ្យមានសេចក្តីវិនាស។ ព្រះកំពុងមានបន្ទូលនឹងសត្វពស់ថា «អ្វីដែលឯងបានធ្វើនឹងមិននៅជារហូតទេ។ ឯងនឹងត្រូវវិនាស ហើយនិងអ្វីទាំងអស់ដែលអាក្រក់នឹងត្រូវវិនាសជាមួយនឹងឯង»។ បណ្តាសាររបស់ព្រះលើសត្វពស់បើកទ្វារសេចក្តីសង្ឃឹមសម្រាប់យើង។ រួចព្រះបានមានបន្ទូលទៅអ័ដាមថា «ដីត្រូវបណ្តាសាដោយព្រោះឯង» (លោកុប្បត្តិ ៣:១៧)។ ដីមិនបានធ្វើអ្វីខុសនោះទេ! អ័ដាមសមនឹងទទួលបណ្តាសាដោយព្រោះអំពើបាបរបស់គាត់។ ប៉ុន្តែព្រះបានបង្វែរបណ្តាសាចេញពីមនុស្សប្រុសនិងមនុស្សស្រីទៅលើដីដើម្បីពួកគេអាចត្រូវបានផ្សះផ្សារជាមួយនឹងព្រះ ជំនួសឲ្យការត្រូវវិនាសជាមួយនឹងសត្វពស់។

តើព្រះសន្យាអ្វី? *ព្រះសន្យាបំផ្លាញការអាក្រក់ ហើយដកយកបណ្តាសារចេញពីលោកិយ។*

តើការនេះនឹងកើតឡើងយ៉ាងដូចម្តេច? ព្រះបានមានបន្ទូលទៅកាន់សាតាំងថា«អញនឹងធ្វើឱ្យឯង ហើយនឹងស្ត្រី គឺទាំងពូជឯងនិងពូជនាង មានសេចក្តីខ្មាំងនឹងគ្នា ពូជនាងនឹងកិនក្បាលឯង ហើយឯងនឹងចឹកកែងជើងគេ»(លោកុប្បត្តិ៣:១៥)។

មនុស្សជាតិតែងតែមានជម្លោះជាមួយនឹងការអាក្រក់។ ការនេះគឺពិតសម្រាប់មនុស្សម្នាក់ៗនៅក្នុងវប្បធម៌និមួយៗក្នុងជំនាន់និមួយៗ។ ប៉ុន្តែព្រះបានមានបន្ទូលអំពីពូជពង្សដែលជាម្នាក់ដែលនឹងមកក្នុងខ្សែប្រវត្តិសាស្រ្តរបស់មនុស្សជាតិ

ហើយកើតពីស្ត្រីមក។ ម្នាក់នោះនឹងឈរនៅខាងយើង។ ទ្រង់នឹងឈរជាមួយយើងក្នុងជម្លោះដ៏ធំនេះ ហើយធ្វើការសម្រាប់យើងដើម្បីប្រឆាំងនឹងអំណាចទាំងអស់របស់ការអាក្រក់។ សាតាំងនឹងចឹកកែងជើងរបស់ទ្រង់ ប៉ុន្តែសូម្បីតែសត្វពស់ចឹកកែងជើងរបស់ទ្រង់ក៏ដោយ ក៏អ្នកជើងឯករបស់យើងនឹងកិនក្បាលរបស់សត្វពស់។

ជីវិតរបស់អ័ដាមនិងអេវ៉ាបានបន្តនៅខាងក្រៅសួនច្បារអេដែន។ ព្រះគុណនៃព្រះបានសង្គ្រោះពួកគេចេញពីការវិនិច្ឆ័យភ្លាមៗ ហើយបានផ្តល់ឲ្យពួកគេនូវសេចក្តីសង្ឃឹមដែលពួកគេនឹងត្រូវបានស្តារឡើងវិញ ប៉ុន្តែពួកគេបានរកឃើញភ្លាមថាមានការផ្លាស់ប្តូរដ៏អាក្រក់នៅក្នុងខ្លួនពួកគេនិងជុំវិញ ដែលនេះមកពីគេមិនស្តាប់បង្គាប់ព្រះជាម្ចាស់នៅក្នុងសួនច្បារអេដែន។

គ្រួសារដំបូងរបស់មនុស្សជាតិត្រូវបានបែកបាក់នៅពេលកាអ៊ីនបានសម្លាប់អេបិលជាប្អូនខ្លួន ហើយបានរស់នៅក្នុងជីវិតភ័យខ្លាចថា ទង្វើរបស់គាត់នឹងត្រូវបានគេសងសឹក (លោកុប្បត្តិ ៤)។ យើងមើលឃើញរួចហើយថា ការដឹងពីការអាក្រក់គឺជាបញ្ហាមួយ។ វាបានបំបែកមនុស្សប្រុសនិងមនុស្សស្រីចេញពីព្រះរួចទៅហើយ។ ឥឡូវនេះវាកំពុងបំបែកបំបាក់ក្រុមគ្រួសារមួយ។

នៅពេលអំពើហឹង្សាបានកើនឡើង មនុស្សបានមកផ្តុំគ្នាដើម្បីសាងសង់ទីក្រុងមួយ ដោយសង្ឃឹមថា សន្តិសុខរួមគ្នានឹងជាដំណោះស្រាយ (លោកុប្បត្តិ ១១)។ ប៉ុន្តែទោះបើការសាងសង់ទីក្រុងបានចាប់ផ្តើមដោយសេចក្តីសង្ឃឹមដ៏ធំក៏ដោយ ក៏វាបានបញ្ចប់ដោយការខកចិត្តនៅពេលមនុស្សត្រូវកំចាត់កំចាយទៅទិសខាងជើង ខាងត្បូង ខាងកើត និងខាងលិច ដោយសេចក្តីភ័យខ្លាចនិងបែកខ្ញែកដោយភាសា។

បន្ទាប់មកព្រះបានជ្រើសរើសបុរសម្នាក់ចេញពីពូជអំបូរនិងជាតិសាសន៍ទាំងអស់ក្នុងលោកិយ។

## ការជ្រើសរើស

«អញនឹងឲ្យពរដល់ឯង...ឯងនឹងបានធ្វើជាទីបញ្ចេញពរ...គ្រប់ទាំងគ្រួនៅផែនដីនឹងបានពរដោយសារឯង» (លោកុប្បត្តិ ១២:២-៣)។ អ័ប្រាហាំមិនដឹងអ្វីទាំងអស់អំពីព្រះ។ គាត់គឺជាអ្នកថ្វាយបង្គំរូបព្រះដែលរស់នៅក្នុងសេចក្តីងងឹតខាងវិញ្ញាណទាំងស្រុង (យ៉ូស្វេ ២៤:២)។ ប៉ុន្តែព្រះបានយាងមកក្នុងជីវិតរបស់គាត់ដោយគ្មានការអញ្ជើញហើយផ្លាស់ប្រែគាត់ជារៀងរហូត។

ប្រសិនបើព្រះបានរង់ចាំអ្នកឬខ្ញុំស្ម័គ្រចិត្តដើរតាមទ្រង់ នោះទ្រង់នឹងនៅតែកំពុងរង់ចាំយើង។ គ្មានអ្នកណាស្វែងរកទ្រង់នោះទេ (រ៉ូម ៣:១១)។ គ្មានអ្នកណាសោះ! តាមនិស្ស័យរបស់យើងគឺយើងគេចចេញពីព្រះ។ ប្រសិនបើយើងស្វែងរកទ្រង់នោះដោយព្រោះទ្រង់បានចាប់ផ្តើមស្វែងរកយើងជាមុនហើយទាញយើងទៅឯទ្រង់ទេ។ ព្រះបានបញ្ជាក់ច្បាស់ចំពោះអ័ប្រាហាំថា នេះគឺជាអ្វីដែលទ្រង់មានព្រះទ័យធ្វើនៅក្នុងជីវិតរបស់មនុស្សពីគ្រប់ជាតិសាសន៍នៅលើផែនដី។ ព្រះនឹងប្រមូលមនុស្សពីគ្រប់ជាតិសាសន៍និងភាសា ពីគ្រប់កំរិតការសិក្សានិងប្រាក់ចំណូល ហើយនាំពួកគេទៅក្នុងចំណេះដឹងពេញលេញលើព្រះពររបស់ទ្រង់។

តើព្រះកំពុងតែសន្យាអ្វីឥឡូវនេះ? *ព្រះសន្យានឹងប្រទានពរដល់មនុស្សពីគ្រប់ជាតិសាសន៍។*

ព្រះពរនេះនឹងមិនមកដល់មនុស្សពីគ្រប់ជាតិសាសន៍តាមរយៈអ័ប្រាហាំផ្ទាល់ ឬតាមរយៈពូជពង្សរបស់គាត់ជាទូទៅនោះទេ ប៉ុន្តែនឹងមកតាមរយៈក្មេងម្នាក់ដែលហៅថា «ពូជ» ដែលនឹងកើតក្នុងខ្សែស្រឡាយរបស់អ័ប្រាហាំ (កាឡាទី ៣:១៦)។ នេះជាមូលហេតុដែលព្រះគម្ពីរសញ្ញាចាស់បន្តនិទានរឿងរបស់ពូជពង្សរបស់អ័ប្រាហាំ។

អ័ប្រាហាំនិងសារ៉ាបានចាស់ហើយ ហើយពួកគេគ្មានកូននោះទេ។ ប៉ុន្តែតាមរយៈការអស្ចារ្យរបស់ព្រះគុណនៃព្រះ សារ៉ាបានមានផ្ទៃពោះក្នុងវ័យចំណាស់របស់នាង ហើយបានបង្កើតកូនប្រុសម្នាក់ឈ្មោះថា អ៊ីសាក។ កូនប្រុសរបស់អ៊ីសាកឈ្មោះយ៉ាកុប បានមានកូនប្រុសចំនួនដប់ពីរនាក់ដែលបានក្លាយជាឪពុករបស់ពូជអំបូរទាំងដប់ពីររបស់អ៊ីស្រាអែល។

ព្រះបានយកព្រះទ័យទុកដាក់សម្រាប់គ្រួសារដែលរីកផ្សាយនេះក្នុងរបៀបពិសេសមួយ។ នៅពេលអំណត់បានគំរាមកំហែងជីវិតរបស់ពួកគេ ព្រះបានប្រទានអាហារដល់ពួកគេនៅក្នុងស្រុកអេស៊ីព្ទ។ ច្រើនឆ្នាំបន្ទាប់ ព្រះបានប្រទានពរដល់ពួកគេដោយការចំរើនពួកមនុស្សរបស់ពួកគេដើម្បីឲ្យគ្រួសារដែលរីកផ្សាយពីចំនួនចិតសិបនាក់បានកើនដល់សហគមន៍មួយដែលមានមនុស្សចំនួនប្រហែលពីរលាននាក់ក្នុងកំឡុងពេលប្រហែលបួនរយឆ្នាំ។

គេបានមើលងាយប្រជារាស្ត្ររបស់ព្រះនៅពេលពួកគេបានកើនចំនួនមនុស្ស។ ពួកសាសន៍អេស៊ីព្ទបានធ្វើទុក្ខគេដោយភាពសាហាវខ្លាំងបំផុតហើយពួកអ៊ីស្រាអែលបានក្លាយទៅជាទាសករនៅក្នុងស្រុកអេស៊ីព្ទ។ ប៉ុន្តែព្រះបានទតឃើញការរងទុក្ខរបស់ពួកគេ ហើយមានសេចក្តីមេត្តាករុណាចំពោះពួកគេ។

## សេចក្តីប្រោសលោះ

ព្រះអម្ចាស់បានមានបន្ទូលថា «អញបានឃើញសេចក្តីវេទនារបស់រាស្ត្រអញដែលនៅស្រុកអេស៊ីព្ទ...ដូច្នេះអញបានចុះមកដើម្បីនឹងជួយដោះគេឲ្យរួចចេញពីកណ្តាប់ដៃនៃពួកសាសន៍អេស៊ីព្ទ អញនឹងនាំគេឡើងចេញពីស្រុកនោះ ទៅឯស្រុកយ៉ាងល្អដ៏ធំទូលាយ ជាស្រុកដែលមានទឹកដោះនិងទឹកឃ្មុំហូរហៀរវិញ» (និក្ខមនំ ៣:៧-៨)។ ព្រះបានលើកបុរសម្នាក់ឡើងគឺម៉ូសេ ហើយបញ្ជូនគាត់ទៅឯស្តេចរបស់អេស៊ីព្ទដែលមិនជឿព្រះអម្ចាស់ជាមួយនឹងសេចក្តីបង្គាប់នេះ «ចូរដោះលែងរាស្ត្ររបស់អញ» (និក្ខមនំ ៥:១)។ ស្តេចមិនបានទទួលស្គាល់អំណាចរបស់ព្រះនោះទេ ដូច្នេះស្តេចបានបដិសេធសេចក្តីបង្គាប់របស់ព្រះ ហើយក៏ត្រូវទទួលការវិនិច្ឆ័យរបស់ព្រះ។ ព្រះបានបញ្ជូនគ្រោះកាចមួយក្រុមដែលបាននាំទៅដល់ការវិនិច្ឆ័យដែលវិនាសមួយដែលមានសេចក្តីស្លាប់ពេញទឹកដីអេស៊ីព្ទទាំងមូល។

មុនពេលព្រះបានបញ្ជូនការវិនិច្ឆ័យនេះ ទ្រង់បានប្រទានឲ្យរាស្ត្ររបស់ទ្រង់នូវសេចក្តីបង្គាប់និងសេចក្តីសន្យាមួយៈ គ្រួសារនិមួយៗត្រូវសម្លាប់ចៀមមួយហើយយកឈាមរបស់វាលាបលើក្របទ្វាររបស់គេដើម្បីបង្ហាញថាសេចក្តីស្លាប់បានមកដល់ផ្ទះរបស់ពួកគេរួចទៅហើយ (និក្ខមនំ ១២:៧)។ បន្ទាប់មកព្រះបានមានបន្ទូលថា «កាលណាអញឃើញឈាមនោះ អញនឹងរំលងផុតពីឯងរាល់គ្នាទៅ» (និក្ខមនំ ១២:១៣)។

នៅយប់នៃពិធីបុណ្យរំលង យញ្ញបូជារបស់ព្រះបាននាំរាស្ត្ររបស់ទ្រង់ចេញពីទាសភាព ហើយបានរំដោះពួកគេចេញពីការវិនិច្ឆ័យរបស់ទ្រង់។ បន្ទាប់ពីនេះព្រះបានធ្វើសម្ពន្ធមេត្រីជាមួយពួកគេ «អញនឹងដើរនៅកណ្តាលពួកឯង ព្រមទាំងធ្វើជាព្រះដល់ឯងរាល់គ្នា ហើយឯងរាល់គ្នានឹងធ្វើជារាស្ត្រដល់អញ» (លេវីវិន័យ ២៦:១២)។

ព្រះបានប្រទានឲ្យរាស្ត្ររបស់ទ្រង់នូវបទបញ្ញានិងយញ្ញបូជា។ យើងត្រូវការបទបញ្ញាដោយព្រោះព្រះហៅឲ្យរាស្ត្ររបស់ទ្រង់ដើរនៅក្នុងផ្លូវរបស់ទ្រង់។ អស់អ្នកណាដែលទទួលព្រះនាមរបស់ទ្រង់ត្រូវមានអត្តចរិតរបស់ទ្រង់។ ប៉ុន្តែរាស្ត្ររបស់ព្រះត្រូវការលើសជាងក្រឹត្យវិន័យទៅទៀត។ យើងត្រូវការយញ្ញបូជាដោយព្រោះទោះអស់ពីសមត្ថភាពរបស់យើង ក៏យើងនៅតែជាពួកមនុស្សមានបាបដែលខ្វះមិនដល់សិរីល្អរបស់ព្រះដដែល។

រាស្ត្ររបស់ព្រះត្រូវបានរំដោះចេញពីការវិនិច្ឆ័យដោយឈាមរបស់ចៀមមួយដែលគេសម្លាប់។ ក្នុងរបៀបដូចគ្នាទំនាក់ទំនងរបស់ពួកគេជាមួយព្រះត្រូវទ្រទ្រង់ដោយយញ្ញបូជាដែលបានផ្តល់ឲ្យសម្រាប់អំពើបាបរបស់ពួកគេ។ តើអ្វីដែលព្រះកំពុងសន្យាឥឡូវនេះ? ព្រះសន្យានឹងផ្សះផ្សារពួកមនុស្សមានបាបនឹងអង្គទ្រង់តាមរយៈយញ្ញបូជាមួយ។

រាស្ត្ររបស់ព្រះមិនបានស្កប់ចិត្តនឹងអ្វីដែលព្រះបានប្រទានឲ្យនោះទេ គឺពួកគេចង់បានស្តេចមួយអង្គ។ ព្រះបានប្រទានស្តេចមួយអង្គដែលពួកគេចង់បាន ហើយស្តេចនោះគឺជាមហន្តរាយដល់ពួកគេវិញ។ បន្ទាប់មកព្រះបានប្រទានស្តេចមួយអង្គទៀតដល់ពួកគេ គឺដាវីឌ ហើយព្រះបានប្រទានសេចក្តីសន្យាពិសេសមួយដល់ដាវីឌ។

## អំណាចគ្រប់គ្រង

«អញនឹងតាំងពូជពង្សដែលកើតពីឯងមក ឲ្យសោយរាជ្យឡើងជំនួសឯង ហើយអញនឹងតាំងរាជ្យវាឲ្យខ្ជាប់ខ្ជួនឡើង។ គឺវាដែលនឹងស្អាងវិហារមួយសម្រាប់ឈ្មោះអញ ហើយអញនឹងតាំងបល្ល័ងនៃរាជ្យវាឲ្យនៅស្ថិតស្ថេរជាដរាបទៅ» (២សាំយ៉ូអែល ៧:១២-១៣)។

រាស្ត្ររបស់ព្រះបានមានព្រះពររបស់ទ្រង់ក្នុងកំឡុងពេលរបស់ស្ដេចដាវីឌដែលលើសជាងអ្វីៗទាំងអស់ដែលពួកគេបានដឹងពីមុន។ រាស្ត្ររបស់ព្រះបានរុងរឿងដោយពួកខ្មាំងសត្រូវរបស់ពួកគេត្រូវចុះចាញ់ ហើយព្រំដែនរបស់ពួកគេមានសន្តិសុខល្អ។ ប៉ុន្តែតើអ្វីនឹងកើតឡើងបន្ទាប់ពីដាវីឌ?

គ្រប់ឪពុកទាំងអស់ចង់បានល្អបំផុតសម្រាប់កូនប្រុសរបស់ខ្លួនដូច្នេះដាវីឌចាប់អារម្មណ៍ចំពោះព្រះនៅពេលទ្រង់បានមានបន្ទូលអំពីពូជពង្សរបស់ដាវីឌៈ ព្រះសន្យានឹងលើកបុត្រារបស់ដាវីឌផ្ទាល់ ហើយនឹងតាំងរាជ្យរបស់ដាវីឌ។ បុត្រារបស់ដាវីឌនឹងបំពេញសម្រេចសេចក្តីសង្ឃឹមរបស់ដាវីឌក្នុងការសាងសង់តំណាក់មួយសម្រាប់ព្រះនាមព្រះ។

បន្ទាប់មកព្រះបានប្រទានសេចក្តីសន្យាដ៏អស្ចារ្យមួយដែលដាវីឌត្រូវតែអង្គុយចុះទទួលយកវា។ ព្រះបានសន្យានឹងតាំងរាជ្យរបស់បុត្រារបស់ដាវីឌជាដរាបទៅ ហើយទ្រង់បានមានបន្ទូលថា «អញនឹងធ្វើជាឪពុកដល់វា ហើយវានឹងបានជាកូនដល់អញ» (២សាំយ៉ូអែល ៧:១៤)។ ដំបូងសេចក្តីសន្យានេះសំដៅលើសាឡូម៉ូនជាបុត្រារបស់ដាវីឌដែលគ្រងរាជ្យបន្ទាប់ពីដាវីឌ។ ប៉ុន្តែសេចក្តីសន្យាអំពីរាជ្យវង្សដ៏អស់កល្បជានិច្ចរបស់ដាវីឌ (២សាំយ៉ូអែល ៧:១៦) ប្រមើលទុកជាមុនអំពីបុត្រាមួយដែលនឹងធំជាងទាំងដាវីឌនិងសាឡូម៉ូនទៅទៀត។ តើរាជ្យបល្ល័ងណាមួយដែលនឹងគង់នៅជាដរាបទៅ? ហើយតើបុត្រារបស់ដាវីឌក៏អាចជាបុត្រារបស់ព្រះដែរយ៉ាងដូចម្ដេច?

នៅពេលយើងធ្វើដំណើរឆ្លងកាត់រឿងនៅក្នុងព្រះគម្ពីរសញ្ញាចាស់ យើងកំពុងសាងសង់រូបភាពមួយនៃផែនការរបស់ព្រះ ហើយនឹងរូបភាពនៃម្នាក់ដែលនឹងប្រទានអ្វីដែលព្រះសន្យានឹងប្រទានជីវិតដល់មនុស្សដែលនឹងបញ្ចេញសិរីល្អរបស់ទ្រង់ ដោយសន្យានឹងបំផ្លាញការអាក្រក់ហើយយកលោកិយចេញពីបណ្ដាសាររបស់វា សន្យានឹងប្រទានពរដល់មនុស្សពីគ្រប់ជាតិសាសន៍ ហើយសន្យានឹងផ្សះផ្សារពួកមនុស្សមានបាបនឹងអង្គទ្រង់តាមរយៈយញ្ញបូជាមួយសម្រាប់អំពើបាប។

ម្នាក់ដែលនឹងបំពេញសម្រេចសេចក្តីសន្យានេះ នឹងកើតពីស្ត្រីម្នាក់ ទ្រង់នឹងជាពូជរបស់អ័ប្រាហាំ និងជាពូជពង្សរបស់ដាវីឌ ជាស្តេចមួយអង្គដែលនឹងនាំព្រះពរនៃការគ្រប់គ្រងរបស់ព្រះ។ ព្រះនឹងធ្វើជាឪពុករបស់ទ្រង់ ហើយទ្រង់នឹងជាកូនរបស់ព្រះ។ ព្រះនឹងតាំងបល្ល័ង្ករាជ្យរបស់ទ្រង់ជាដរាបទៅ។ តើឥឡូវ នេះព្រះកំពុងសន្យាអំពីអ្វី? ព្រះសន្យាថា រាស្ត្ររបស់ទ្រង់នឹងរស់នៅក្រោមព្រះពរនៃការគ្រប់គ្រងរបស់ទ្រង់ជាដរាបទៅ។

បន្ទាប់ពីដាវីឌមានរាជ្យវង្សបន្តមកទៀត ខ្លះល្អ ប៉ុន្តែភាគច្រើនអាក្រក់។ រាស្ត្ររបស់ព្រះបានថ្វាយបង្គំព្រះដទៃនិងបានដើរតាមផ្លូវរបស់ព្រះដទៃទាំងនោះ។ ព្រះបានបញ្ជូនអ្នកនាំសារដែលហៅថា «ពួកហោរា» ដើម្បីហៅឲ្យរាស្ត្ររបស់ទ្រង់ត្រឡប់មកការស្ដាប់បង្គាប់វិញ។ ស្ទើរគ្រប់ពេលពួកគេព្រងើយកន្តើយនឹងព្រះរាជសាររបស់ពួកហោរា។ដូច្នេះ ព្រះដែលមានព្រះបន្ទូលមិនដែលបរាជ័យ បានធ្វើសកម្មភាពដើម្បីដាក់វិន័យនិងកែប្រែរាស្ត្ររបស់ទ្រង់។

## ការកែប្រែ

«ដ្បិតព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ លុះកាលបានសម្រេចគ្រប់៧០ឆ្នាំនៅក្រុងបាប៊ីឡូនហើយ នោះអញនឹងប្រោសឯងរាល់គ្នា ហើយនឹងធ្វើសម្រេចដល់ឯងរាល់គ្នា តាមពាក្យល្អរបស់អញដោយធ្វើឲ្យឯងរាល់គ្នាវិលមកឯទីនេះវិញ ដ្បិតព្រះយេហូវ៉ាទ្រង់មានបន្ទូលថា អញស្គាល់សេចក្តីដែលអញគិតពីដំណើរឯងរាល់គ្នា មិនមែនគិតធ្វើសេចក្តីអាក្រក់ទេ គឺគិតឲ្យបានសេចក្តីសុខវិញ ដើម្បីដល់ចុងបំផុត ឲ្យឯងរាល់គ្នាបានសេចក្តីសង្ឃឹម» (យេរេមា២៩:១០-១១)។

ខ្មាំងសត្រូវបានលុកលុយទឹកដីដែលព្រះបានប្រទានឲ្យរាស្ត្ររបស់ទ្រង់ ហើយរាស្ត្ររបស់ទ្រង់ត្រូវបាននិរទេស។ ពួកគេបានរស់នៅបាប៊ីឡូនក្រោមការដាក់វិន័យរបស់ព្រះ ហើយបានសំអាតផ្លូវរបស់ពួកគេតាមរយៈទុក្ខលំបាកនិងការប្រែចិត្តអស់រយៈពេលចិតសិបឆ្នាំ។

ប៉ុន្តែសូម្បីតែក្នុងការដាក់វិន័យធ្ងន់ធ្ងន់បំផុតបែបនេះក៏ដោយ ក៏ព្រះកំពុងធ្វើឲ្យគោលបំណងរបស់ទ្រង់ចំរើនទៅមុខសម្រាប់រាស្ត្ររបស់ទ្រង់ដែរ។ ព្រះទទួលយកយើងនៅក្នុងអំពើបាបរបស់យើង ប៉ុន្តែទ្រង់មិនដែលទុកយើងរស់នៅនៅក្នុងអំពើបាបរបស់យើងនោះឡើយ។ ទ្រង់មិនឈប់នឹងហៅយើងឲ្យដើរតាមផ្លូវរបស់ទ្រង់ ហើយមិនឈប់នឹងកែប្រែយើងនៅពេលយើងឃ្លាតឆ្ងាយពីផ្លូវរបស់ទ្រង់នោះឡើយ។

នៅពេលការងារប្រោសលោះរបស់ព្រះនៅក្នុងជីវិតបានចប់សព្វគ្រប់ នោះអ្នកនឹងស្រលាញ់ព្រះដោយអស់អំពីចិត្តអស់អំពីគំនិត អស់អំពីព្រលឹង និងអស់អំពីកំលាំង ព្រមទាំងនឹងស្រលាញ់អ្នកជិតខាងរបស់អ្នកដូចជាខ្លួនឯង ហើយអ្នកនឹងចែករំលែកសេចក្តីអំណរនៃសេចក្តីស្រលាញ់នេះជាមួយរាស្ត្រទាំងអស់របស់ព្រះអស់កល្បជានិច្ច។

រហូតដល់ថ្ងៃនោះ ព្រះនឹងមិនសម្រាកនៅពេលរាស្ត្ររបស់ទ្រង់នៅជាប់ជាមួយអំពើបាបដែលទ្រង់បានប្រាប់យើងឲ្យបោះបង់ចោលរួចមកហើយនោះទេ។ ព្រះមិនមានគោលបំណង នាំពួកមនុស្សមានបាបដែលមិនបានផ្លាស់ប្រែនិងនៅអាត្មានិយមចូលទៅក្នុងសេចក្តីអំណរនៃជីវិតអស់កល្បនោះឡើយ។ ព្រះហៅឲ្យយើងមកឯការស្តាប់បង្គាប់ ហើយនៅពេលយើងបដិសេធការហៅរបស់ទ្រង់ នោះយើងគួរតែរំពឹងចង់មករស់នៅក្រោមការដាក់វិន័យដោយក្តីស្រលាញ់របស់ទ្រង់ដែលមិនអនុញ្ញាតឲ្យយើងទៅចុះ។

បន្ទាប់ពីចិតសិបឆ្នាំ ព្រះបាននាំរាស្ត្រដែលត្រូវវាយផ្ចាលរបស់ទ្រង់ត្រឡប់មកទឹកដីសន្យាវិញ។ ការស្តារឡើងវិញនេះគឺជាការអស្ចារ្យនៃព្រះគុណនៃព្រះដែលហាក់ដូចជាមិនអាចទៅរួច។ ប៉ុន្តែបន្ទាប់មកព្រះបានប្រទានឲ្យបុរសម្នាក់នូវនិមិត្តមួយអំពីអ្វីដែលទ្រង់ហៀបនឹងធ្វើ។

## ការស្តារឡើងវិញ

«រួចទ្រង់មានបន្ទូលមកខ្ញុំថា កូនមនុស្សអើយ ឆ្អឹងទាំងនេះជាពួកវង្សអ៊ីស្រាអែលទាំងមូល មើល គេនិយាយថា ឆ្អឹងយើងរាល់គ្នាស្ងួតហែងហើយ ទីសង្ឃឹមរបស់យើងក៏បាត់អស់ទៅ យើងរាល់គ្នាត្រូវកាត់ចេញស្រ ឡះផង ដូច្នេះ ចូរទាយប្រាប់គេថា ព្រះអម្ចាស់យេហូវ៉ាទ្រង់មាន បន្ទូលដូច្នេះ ម្នាលរាស្ត្រអញអើយ អញនឹងបើកផ្នូរខ្មោចរបស់ឯងរាល់គ្នា ហើយនឹងធ្វើឲ្យឯងរាល់គ្នាឡើងចេញពីផ្នូរមក រួចនឹងនាំឯងឲ្យ ចូលទៅក្នុងស្រុកអ៊ីស្រាអែលវិញឱរាស្ត្រអញអើយ ឯងរាល់គ្នានឹងដឹងថា អញនេះជាព្រះយេហូវ៉ាពិត ក្នុងកាលដែលអញបើកផ្នូររបស់ឯង ឲ្យឯងបានឡើងចេញពីនោះមក» (អេសេគាល៣៧:១១-១៣)។

សេចក្តីសន្យារបស់ព្រះធំអស្ចារ្យដែលសេចក្តីជំនឿដើរទ្រេតទ្រេតនៅមុខពួកវា។ ដូចជាសេចក្តីសន្យាដែលព្រះអង្គបានប្រកាសដល់រាស្ត្ររបស់ព្រះនៅក្នុងសម័យអេសេគាល។ ក្រុងយេរូសាឡឹមនៅបាក់បែក ប្រជាជនរបស់ក្រុងនេះភាគច្រើនបានរត់ភៀសខ្លួនឬបានស្លាប់ ហើយអស់អ្នកដែលនៅមានជីវិតគឺជាអ្នកត្រូវនិរទេសនៅក្នុងបាប៊ីឡូនក្រោមរបបមួយដែលមិនអនុញ្ញាតដោះលែងពួកគេនោះទេ។

រាស្ត្ររបស់ព្រះបានដឹងអំពីសេចក្តីសន្យារបស់ទ្រង់ ប៉ុន្តែគេឃើញសេចក្តីវិនាសដែលមកដោយការអាក្រក់ ដូច្នេះព្រះពររបស់ព្រះលើគ្រប់ជាតិសាសន៍ និងអំណរនៃនគររបស់ដាវីឌហាក់ដូចជានៅឆ្ងាយពីជីវិតប្រចាំថ្ងៃរបស់ពួកគេខ្លាំងណាស់។ វាជាការពិបាកសម្រាប់រាស្ត្ររបស់ទ្រង់ក្នុងការច្រៀងសរសើរទ្រង់នៅក្នុងទឹកដីដទៃនេះ។

បន្ទាប់មកព្រះបានប្រទានឲ្យហោរាអេសេគាលនូវនិមិត្តមួយដែលគាត់បានឃើញជ្រលងភ្នំដែលមានឆ្អឹងស្ងួត។ រូបភាពនេះស៊ីគ្នានឹងអារម្មណ៍របស់រាស្ត្ររបស់ព្រះដែលកំពុងនិយាយថា «ឆ្អឹងយើងរាល់គ្នាស្ងួតហែងហើយ ទីសង្ឃឹមរបស់យើងក៏បាត់អស់ទៅ យើងរាល់គ្នាត្រូវកាត់ចេញស្រឡះផង» (អេសេគាល ៣៧:១១)។ ពួកគេបានមានអារម្មណ៍ថា ស្ថានភាពរបស់ពួកគេគឺអស់សង្ឃឹម។

នៅក្នុងនិមិត្ត អេសេគាលបានប្រកាសព្រះបន្ទូលនៃព្រះទៅកាន់ឆ្អឹងទាំងនោះ ហើយនៅពេលគាត់បានប្រកាស នោះឆ្អឹងបានផ្គុំគ្នា។ បន្ទាប់មកឆ្អឹងទាំងនោះគ្របដោយសរសៃ សាច់និងស្បែក ហើយវិញ្ញាណរបស់ព្រះបានផ្លុំជីវិតទៅក្នុងសាក

សពទាំងនោះ ដូចដែលទ្រង់បានផ្ដុំជីវិតទៅក្នុងអ័ដាមផងដែរ។ ព្រះបានកំពុងនាំមកនូវជីវិតថ្មីចេញពីផ្នូរ។ តើអ្វីដែលព្រះសន្យាឥឡូវនេះ? ព្រះសន្យាជីវិតថ្មីចេញពីផ្នូរ។

### ការសន្និដ្ឋាន

ព្រះគម្ពីរសញ្ញាចាស់គឺជារឿងនៃសេចក្ដីសន្យាដ៏អស្ចារ្យរបស់ព្រះ។

១. ព្រះសន្យានឹងប្រទានជីវិតដល់មនុស្សដែលឆ្លុះបញ្ចាំងសិរីល្អរបស់ទ្រង់។

២. ព្រះសន្យានឹងបំផ្លាញការអាក្រក់ និងនាំលោកិយចេញពីបណ្ដាសាររបស់វា។

៣. ព្រះសន្យានឹងប្រទានពរដល់មនុស្សគ្រប់ជាតិសាសន៍។

៤. ព្រះសន្យានឹងផ្សះផ្សារពួកមនុស្សមានបាបនឹងទ្រង់តាមរយៈយញ្ញបូជាមួយសម្រាប់អំពើបាប។

៥. ព្រះសន្យាថា រាស្ត្ររបស់ទ្រង់នឹងរស់នៅក្រោមព្រះពរនៃការគ្រប់គ្រងរបស់ទ្រង់ជាដរាបទៅ។

៦. ព្រះសន្យាថា រាស្ត្រទាំងអស់របស់ទ្រង់នឹងដើរក្នុងផ្លូវរបស់ទ្រង់។

៧. ព្រះសន្យានឹងនាំមកនូវជីវិតថ្មីចេញពីផ្នូរ។

ទាំងនេះគឺជាសេចក្ដីសន្យាដ៏អស្ចារ្យ។ មានតែព្រះទេដែលអាចធ្វើការសន្យាទាំងនេះ ហើយមានតែព្រះទេដែលអាចបំពេញសេចក្ដីសន្យាទាំងនេះបាន។ ដើម្បីដឹងអំពីរបៀបដែលទ្រង់បានធ្វើការនេះ ហើយដើម្បីមើលឃើញរបៀបសេចក្ដីសន្យាទាំងនេះទាក់ទងនឹងជីវិតរបស់អ្នក នោះយើងងាកមកកងព្រះគម្ពីរសញ្ញាថ្មីវិញម្ដង។

## *ព្រះគ្រីស្ទបំពេញសម្រេចសេចក្ដីសន្យា: រឿងក្នុងកណ្ដាដំណឹងល្អ*

ព្រះធ្វើការសន្យាដ៏ធំអស្ចារ្យដែលមានតែទ្រង់ផ្ទាល់ទេដែលអាចបំពេញសម្រេចពួកវាបាន ដូច្នេះព្រះបានយកនិស្ស័យជាមនុស្សនៅក្នុងព្រះយេស៊ូវគ្រីស្ទ។ ព្រះអាទិករបានចូលទៅក្នុងស្នាព្រះហស្តរបស់ទ្រង់ផ្ទាល់។ ព្រះបានយាងមកហើយឈរជាមួយនឹងយើង ធ្វើការសម្រាប់យើង ដើម្បីបំពេញសម្រេចសេចក្ដីសន្យារបស់ទ្រង់ផ្ទាល់។ ព្រះបន្ទូលដែលគង់នៅជាមួយព្រះ ហើយព្រះបន្ទូលនោះឯងជាព្រះ ហើយគ្រប់ទាំងអស់បានកើតមកដោយសារទ្រង់ បានត្រឡប់ជាសាច់ឈាម និងគង់នៅកណ្ដាលពួកយើង (យ៉ូហាន ១:២, ១៤)។

### ការយកនិស្ស័យជាមនុស្ស

«ទេវតាក៏ឆ្លើយថាព្រះវិញ្ញាណបរិសុទ្ធនឹងយាងមកសណ្ឋិតលើនាងហើយព្រះចេស្ដានៃព្រះដ៏ខ្ពស់បំផុតនឹងមកគ្របបាំងនាងដោយស្រមោលហេតុដូច្នេះបុត្របរិសុទ្ធដែលនឹងប្រសូតមកនោះត្រូវហៅថាជាព្រះរាជបុត្រានៃព្រះ» (លូកា ១:៣៥)។

ទេវតាបានប្រកាសទៅនាងម៉ារាថា ព្រះយេស៊ូវនឹងជា «ព្រះរាជបុត្រានៃព្រះដ៏ខ្ពស់បំផុត» ហើយជា «ព្រះរាជបុត្រានៃព្រះ» (លូកា ១:៣២, ៣៥) ហើយម៉ាថាយកត់ត្រាថា ទ្រង់គឺជា «ព្រះអង្គគង់ជាមួយនឹងយើងខ្ញុំ» (ម៉ាថាយ ១:២៣)។ យ៉ូហានបរិយាយអំពីទ្រង់ជាព្រះបន្ទូលនៃព្រះដែលត្រឡប់ជាសាច់ឈាម (យ៉ូហាន ១:១៤)។

ព្រះបានប្រកាសសេចក្ដីសន្យារបស់ទ្រង់តាមរយៈព្រះបន្ទូល។ បន្ទាប់មកនៅពេលព្រះបន្ទូលរបស់ទ្រង់ត្រឡប់ជាសាច់ឈាម នោះព្រះបានប្រទានសេចក្ដីសន្យារបស់ទ្រង់។ មានតែព្រះទេដែលអាចប្រទានអ្វីដែលព្រះបានសន្យា។ នេះជាមូលហេតុដែលការសរសើរតម្កើងនិងការអរព្រះគុណរបស់គ្រីស្ទបរិស័ទផ្សារភ្ជាប់យ៉ាងជិតស្និទ្ធជាមួយនឹងការសារភាពថា ព្រះយេស៊ូវគឺជាព្រះ ហើយថា ព្រះយេស៊ូវគឺជាមនុស្ស។ ព្រះគ្រីស្ទក៏បានប្រសូត្រមកដូចយើងបានកើតមកដែរ ដើម្បីរស់ជីវិតរបស់យើង និងស្លាប់ការស្លាប់របស់យើង។ ទ្រង់បានយាងមកឯយើង ហើយឈរជាមួយយើងដើម្បីធ្វើការជំនួសយើង។ ក្នុងនាមជាព្រះនោះទ្រង់ប្រទានអ្វីដែលព្រះបានសន្យា ក្នុងនាមជាមនុស្ស នោះទ្រង់ប្រទានអ្វីដែលព្រះបានសន្យាជាមួយយើង។

ទេវតាក៏បានប្រកាសផងដែរថា ព្រះយេស៊ូវគឺបរិសុទ្ធ: «បុត្របរិសុទ្ធ» (លូកា ១:៣៥)។ នេះគឺជាអ្វីដែលមិនដែលបានឃើញពីមុនមកក្នុងប្រវត្តិសាស្ត្ររបស់លោកិយហើយនឹងមិនដែលបានឃើញម្តងទៀតនោះដែរៈ មនុស្សម្នាក់ដែលមានលក្ខណៈបរិសុទ្ធ។ ព្រះគ្រីស្ទមានសិទ្ធិរស់នៅស្ថានសួគ៌ហើយមានសមត្ថភាពនាំអ្នកដទៃទៅកាន់ទីនោះជាមួយទ្រង់ ពីព្រោះទ្រង់គឺជាព្រះ។

ការជួបជុំគ្នារបស់ព្រះនិងមនុស្សនៅក្នុងព្រះយេស៊ូវគ្រីស្ទដែលជាព្រះអង្គបរិសុទ្ធ បើកទ្វារសេចក្តីសង្ឃឹមសម្រាប់យើង។ នេះជាគោលបំណងនៃការយកនិស្ស័យជាមនុស្ស។ បណ្ឌិត ចន កាលវិន និយាយអំពីការនេះបានយ៉ាងល្អ។

> ដោយសារព្រះជាម្ចាស់មិនចេះស្លាប់ហើយមនុស្សមិនអាចឈ្នះលើសេចក្តីស្លាប់ ព្រះយេស៊ូវបានរួមទាំងជាព្រះផងនិងជាមនុស្សផងដើម្បីថ្វាយខ្លួន(ជារូបកាយរបស់មនុស្ស)ជាយញ្ញបូជាឲ្យធួននឹងបាបនិងឈ្នះលើសេចក្តីស្លាប់ដោយអំណាចរបស់ទ្រង់ក្នុងនាមជាព្រះជាម្ចាស់។[២]

## សេចក្តីល្បួង

«រីឯព្រះយេស៊ូវទ្រង់បានពេញជាព្រះវិញ្ញាណបរិសុទ្ធ ក៏វិលពីទន្លេយ័រដាន់មកវិញ នោះព្រះវិញ្ញាណ នាំទៅនៅទីរហោស្ថាន ទ្រង់ត្រូវអារក្សល្បួងក្នុងរវាង៤០ថ្ងៃ មិនបានសោយអ្វីសោះនៅវេលានោះ លុះផុតថ្ងៃទាំងនោះមក ទ្រង់ក៏ឃ្លាន» (លូកា៤:១-២)។

ព្រះគ្រីស្ទបានប្រឈមនឹងសាតាំងនៅពេលព្រះវិញ្ញាណបាននាំទ្រង់ឲ្យត្រូវសាតាំងល្បួង ហើយព្រះគ្រីស្ទបានឈ្នះត្រង់ចំណុចដែលអ័ដាមបានចាញ់។ អារក្សបានល្បួងព្រះយេស៊ូវបីដង ដូចដែលវាបានធ្វើជាមួយអេវ៉ានិងអ័ដាមដែរ។ ភាពស្របគ្នាគឺច្បាស់លាស់ ប៉ុន្តែយើងមិនត្រូវភ្លេចភាពខុសគ្នានោះទេ។

បរិស្ថានគឺពិតជាខុសគ្នា។ អេវ៉ានិងអ័ដាមបានប្រឈមនឹងសេចក្តីល្បួងនៅក្នុងសួនច្បារមួយដែលមានផ្លែឈើប្រទានឲ្យនៅលើដើមឈើផ្សេងៗនៅជុំវិញពួកគេ។ព្រះគ្រីស្ទបានប្រឈមនឹងសេចក្តីល្បួងនៅក្នុងទីរហោស្ថានដែលគ្មានអាហារហើយទ្រង់ឃ្លាន។

មួយទៀត សាតាំងបានមករកស្ត្រីនៅក្នុងសួនច្បារ។ ប៉ុន្តែព្រះគ្រីស្ទយាងទៅរកសាតាំងនៅក្នុងទីរហោស្ថាន។ ព្រះវិញ្ញាណបរិសុទ្ធបាននាំទ្រង់ទៅក្នុងការប្រឈមនឹងអារក្ស។ ព្រះគ្រីស្ទបានចាប់ផ្តើមការប្រឈមជាមួយនឹងសាតាំង។

ភាពខុសគ្នាដែលធំបំផុតគឺលទ្ធផល។អ័ដាមបានចាញ់ ព្រះគ្រីស្ទបានឈ្នះ។ បន្ទាប់ពីល្បួងព្រះគ្រីស្ទ សាតាំងត្រូវបានបង្ខំឲ្យដកថយ «រហូតដល់ពេលវេលាល្អមួយ»(លូកា ៤:១៣)។ ការយកឈ្នះលើព្រះអង្គបរិសុទ្ធដោយសេចក្តីល្បួងគឺពិតជាទៅមិនរួចនោះឡើយ។

ជ័យជំនះរបស់ព្រះគ្រីស្ទលើសេចក្តីល្បួងមានសារៈសំខាន់ដ៏ធំធេងសម្រាប់យើង។ ការបរាជ័យរបស់អ័ដាមបាននាំមកនូវទុក្ខវេទនាសម្រាប់យើង។ គាត់បានហុចបន្តលទ្ធផលនៃការបរាជ័យរបស់គាត់ដល់មនុស្សទាំងអស់។ តាមនិស្ស័យរបស់យើង យើងជារបស់អ័ដាមដែលបានបរាជ័យ។ យើងមានចំណែកក្នុងការបរាជ័យរបស់គាត់។ យើង «នៅក្នុងអំពើបាប» (រ៉ូម ៣:៩)។

ប៉ុន្តែជ័យជំនះរបស់ព្រះគ្រីស្ទនាំមកនូវសេចក្តីសង្ឃឹមសម្រាប់យើង។ ដូចជាអ័ដាមបានហុចបន្តលទ្ធផលនៃការបរាជ័យរបស់គាត់ដល់មនុស្សទាំងអស់ដែលមានជីវិតមកពីអ័ដាម នោះព្រះគ្រីស្ទបានប្រទានបន្តលទ្ធផលនៃជ័យជំនះ របស់ទ្រង់ដល់មនុស្សទាំងអស់ដែលទាញយកជីវិតថ្មីពីទ្រង់។ ដោយព្រះគុណតាមរយៈសេចក្តីជំនឿ យើងជារបស់ព្រះគ្រីស្ទដែលបានជ័យជំនះ។ យើងមានចំណែកនៅក្នុងជ័យជំនះរបស់ទ្រង់។ យើង «នៅក្នុងព្រះគុណ» (រ៉ូម ៦:១៤)។

សេចក្តីកំសោយរបស់អ័ដាមដែលបានបរាជ័យគឺនៅក្នុងអ្នក ដូច្នេះចូរចាំយាមប្រឆាំងនឹងសេចក្តីល្បួង។ ប៉ុន្តែកំលាំងរបស់ព្រះគ្រីស្ទដែលបានជ័យជំនះក៏នៅក្នុងអ្នកដោយព្រះវិញ្ញាណបរិសុទ្ធផងដែរ ដូច្នេះនៅពេលយើងត្រូវសេចក្តីល្បួង

នោះយើងអាចឈរនៅមាំមួន។ បន្ទាប់ពីជ័យជំនះ របស់ទ្រង់នៅក្នុងទីរហោស្ថាន «ព្រះយេស៊ូវទ្រង់វិលទៅ ស្រុកកាលីឡេវិញ ទាំងមានព្រះចេស្ដានៃព្រះវិញ្ញាណសណ្ឋិតលើទ្រង់ នោះមានលឺល្បីពីទ្រង់សុសសាយទូទាំងក្នុងស្រុកនៅជុំវិញ» (លូកា ៤:១៤)។ អ្វីដែលបានកើតឡើងបន្ទាប់មកទៀតនឹងជួយអ្នកឲ្យយល់អំពីជីវិតរបស់យើងនៅក្នុងលោកិយសព្វថ្ងៃនេះ។

## ការបដិសេធ

«ព្រះវិញ្ញាណព្រះអម្ចាស់សណ្ឋិតលើខ្ញុំ ពីព្រោះទ្រង់បានចាក់ប្រេងតាំងខ្ញុំ ឲ្យផ្សាយដំណឹងល្អ ដល់មនុស្សទ័លក្រ ទ្រង់បានចាត់ខ្ញុំឲ្យមក ដើម្បីនឹងប្រោសមនុស្សដែលមានចិត្តសង្រេង ហើយប្រកាសប្រាប់ពីសេចក្ដីប្រោសលោះ ដល់ពួកឈ្លើយ និងសេចក្ដីភ្លឺឡើងវិញដល់មនុស្សខ្វាក់ ហើយអោយដោះមនុស្សដែលត្រូវគេជិះជាន់អោយរួច ព្រមទាំងប្រកាសប្រាប់ពីឆ្នាំដែលព្រះអម្ចាស់កំណត់ទុក...កាលពួកអ្នកនៅក្នុងសាលាប្រជុំបានឮសេចក្ដីទាំង នោះហើយគេមានពេញដោយសេចក្ដីក្រោធ» (លូកា៤:១៨-១៩,២៨)។

ចូរស្រមើស្រម៉ៃថា មានហ្វូងមនុស្សតូចបានផ្ដុំគ្នានៅក្នុងសាលាប្រជុំនៅពេលព្រះយេស៊ូវអានបទគម្ពីរហើយពន្យល់អំពីអត្ថន័យរបស់វា។ ព្រះបន្ទូលរបស់ទ្រង់ពេញដោយសេចក្ដីសង្ឃឹម ប៉ុន្តែមនុស្សមិនឆ្លើយតបដោយអំណរទេ តែដោយកំហឹងវិញ។ ពួកគេ «មានកំហឹង»។ ទោះបើព្រះយេស៊ូវគ្រីស្ទយាងមកហើយបានជួយមនុស្ស ក៏ចាប់ពីដំបូងមានមនុស្សខ្លះបានបដិសេធទ្រង់ ហើយផ្ទៃរឿងនេះបន្តពេញក្នុងកណ្ឌដំណឹងល្អ។

ពេលមួយទៀត ព្រះយេស៊ូវបានព្យាបាលបុរសពិកាដៃម្នាក់។ វាគឺជាការអស្ចារ្យខ្លាំងណាស់ ប៉ុន្តែសូមកត់សម្គាល់ការឆ្លើយតបមកវិញៈ ពួកផារ៉ាស៊ី «មានសេចក្ដីឃោរឃៅពោរពេញក៏ពិគ្រោះគ្នាពីការអ្វីដែលត្រូវធ្វើដល់ព្រះយេស៊ូវ» (លូកា ៦:១១)។ពេលមួយទៀត ព្រះគ្រីស្ទបានដេញអារក្សចេញពីបុរសម្នាក់ដែលបានធ្វើឲ្យសហគមន៍ភ័យតក់ស្លុតដោយអំពើហឹង្សារបស់គាត់។ ប៉ុន្តែនៅពេលមនុស្សបានឃើញបុរសនេះអង្គុយទាំងស្លៀកសំលៀកបំពាក់ហើយដឹងខ្លួនត្រឹមត្រូវវិញ នោះពួកគេបានហៅឲ្យព្រះយេស៊ូវចាកចេញពីតំបន់នោះវិញ (លូកា ៨:៣៧)។

ការបដិសេធនេះបានឡើងដល់ចំនុចកំពូលនៅពេលហ្វូងមនុស្សទទូចឲ្យព្រះយេស៊ូវត្រូវជាប់ឆ្កាង។ ពីឡុតបានព្យាយាមអន្តរាគមន៍ ប៉ុន្តែ «តែគេស្រែកទទូចជាខ្លាំង ទាំងសូមឲ្យឆ្កាងទ្រង់វិញ ហើយសម្រែករបស់ជនទាំងនោះ និងពួកសង្គ្រាជក៏បានឈ្នះ» (លូកា ២៣:២៣)។

យើងរស់នៅក្នុងលោកិយដែលបដិសេធព្រះគ្រីស្ទ។ អ្នកមិនអាចយល់អំពីលោកិយដែលយើងរស់នៅក្នុងនោះទេ រហូតដល់អ្នកយល់ការនេះៈ ព្រះគ្រីស្ទ «បានយាងមកគង់នៅផែនដីរបស់ទ្រង់ តែរាស្ត្រទ្រង់មិនទទួលទ្រង់សោះ» (យ៉ូហាន ១:១១)។

នៅពេលគ្រោះធម្មជាតិកើតឡើង មនុស្សសួរថា «តើហេតុអ្វីព្រះមិនធ្វើអ្វីជាមួយរឿងហ្នឹងអញ្ចឹង?» ប៉ុន្តែនៅពេលទ្រង់បានយាងមកនិងបានធ្វើឲ្យព្យុះស្ងប់ យើងបានបដិសេធទ្រង់ទៅវិញ។ នៅពេលខ្មាន់កាំភ្លើងធ្វើឲ្យសាលារៀនភ័យរន្ធត់ យើងសួរថា «តើហេតុអ្វីព្រះមិនធ្វើអ្វីជាមួយរឿងហ្នឹងអញ្ចឹង?»ប៉ុន្តែនៅពេលទ្រង់បានយាងមកដេញអារក្ស នោះយើងបែរជាបានសុំឲ្យទ្រង់ចាកចេញទៅវិញ។ នៅពេលយើងមានជម្ងឺមហារីកយើងសួរថា «តើហេតុអ្វីព្រះមិនធ្វើអ្វីជាមួយជម្ងឺនេះអញ្ចឹង?» ប៉ុន្តែនៅពេលទ្រង់បានយាងមកនិងបានព្យាបាលអ្នកជម្ងឺ នោះមនុស្សបានបដិសេធទ្រង់ទៅវិញ។

«ទ្រង់បានយាងមកគង់នៅផែនដីរបស់ទ្រង់ តែរាស្ត្រទ្រង់មិនទទួលទ្រង់សោះ»។ អរគុណព្រះអង្គដែលវាមិនបញ្ចប់នៅទីនោះនៅឡើយ។ «ប៉ុន្តែអស់អ្នកណាដែលទទួលទ្រង់ នោះទ្រង់បានប្រទានអំណាច ឲ្យបានត្រឡប់ជាកូនព្រះ» (យ៉ូហាន ១:១២)។

នេះគឺជាឋានៈរបស់យើងជាពួកគ្រីស្ទបរិស័ទៈ យើងរស់នៅក្នុងលោកិយដែលបដិសេធព្រះគ្រីស្ទ ហើយពោរពេញ

ដោយអំពើបាបនិងសេចក្តីស្លាប់ ប៉ុន្តែយើងជារបស់គ្រួសារមួយដែលសរសើរតម្កើងព្រះគ្រីស្ទហើយពោរពេញដោយជីវិតនិងអំណរទាំងអស់របស់គ្រួសារនោះ។ យើងមានការឈឺចាប់របស់លោកិយដែលធ្លាក់ចុះនេះ ហើយមានសេចក្តីសង្ឃឹមរបស់អស់អ្នកដែលនៅក្នុងព្រះគ្រីស្ទផងដែរ។ លោកិយបដិសេធទ្រង់ ហើយព្រះយេស៊ូវបានយាងឡើងលើភ្នំមួយជាមួយសិស្សបីនាក់របស់ទ្រង់។

## ព្រះគ្រីស្ទទៅជាមានរូបរាងប្លែក

«កាលទ្រង់កំពុងតែអធិស្ឋាន នោះបែបភាពព្រះភក្ត្រទ្រង់ក៏ផ្លាស់ប្រែ ហើយព្រះពស្ត្រត្រឡប់ជាសព្រាត» (លូកា ៩:២៩)។

ពេត្រុស យ៉ាកុប និងយ៉ូហានបានមើលឃើញសិរីល្អ ភាពភ្លឺ និងភាពរុងរឿងរបស់ព្រះយេស៊ូវគ្រីស្ទ។ពួកគេបានមើលឃើញអ្វីដែលពួកទេវតាឃើញនៅលើស្ថានសួគ៌ ហើយអ្វីដែលថ្ងៃមួយភ្នែកមនុស្សគ្រប់គ្នានឹងមើលឃើញផងដែរ។ តើពន្លឺចាំងភ្លែតៗរបស់ផ្លេតបន្ទោរភ្លឺយ៉ាងណា? ព្រះយេស៊ូវ(ដែលបុរសទាំងនេះបានស្គាល់ជាមិត្តសម្លាញ់) គឺជាភាពភ្លឺនៃសិរីល្អរបស់ព្រះវរបិតា (ហេព្រើរ ១:៣)។

ប៉ុន្តែមានបុរសពីរនាក់ទៀត ម៉ូសេ និងអេលីយ៉ា បានលេចមកក្នុងភាពរុងរឿងដែលមានសិរីល្អ ហើយនិយាយជាមួយព្រះយេស៊ូវ (លូកា ៩:៣០-៣១)។ ម៉ូសេនិងអេលីយ៉ាបានរស់នៅនិងបានស្លាប់រាប់រយឆ្នាំមុន។ ឥឡូវនេះពួកគេបានលេចមកក្នុងចំណែកនៃសិរីល្អរបស់ព្រះយេស៊ូវ។

បន្ទាប់មកសម្លេងរបស់ព្រះដ៏មានអំណាចព្រះចេស្តារបានមានបន្ទូលពីពពកមកថា «នេះជាកូនស្ងួនភ្ងាអញ ចូរឲ្យស្តាប់តាមចុះ» (លូកា ៩:៣៥)។ លោកិយសព្វថ្ងៃបដិសេធព្រះគ្រីស្ទ។ ប៉ុន្តែព្រះហៅអ្នកឲ្យអ្នកស្តាប់តាមទ្រង់។ ព្រះបានជ្រើសរើសទ្រង់ ហើយទ្រង់អាចនាំមនុស្សស្លាប់ចូលទៅក្នុងសិរីល្អ។

សិស្សទាំងបីនាក់នោះមិនបានស្នាក់នៅលើភ្នំនោះទេ។ ពពករសាត់បាត់ ម៉ូសេនិងអេលីយ៉ាក៏បានបាត់ទៅ ហើយព្រះភ័ក្ត្ររបស់ព្រះយេស៊ូវបានត្រឡប់ជាធម្មតាដូចដែលពួកគេធ្លាប់បានឃើញពីមុន។ ពួកសិស្សត្រូវតែរស់ដោយសេចក្តីជំនឿដូចជាយើងដែរ ហើយនៅពេលពួកគេបានចុះមកពីលើភ្នំ ពួកគេបានដើរត្រឡប់ទៅក្នុងលោកិយដែលពេញដោយការអាក្រក់ដ៏សម្បើមនិងសេចក្តីត្រូវការយ៉ាងខ្លាំង។

## ការជាប់ឆ្កាង

«កាលមកដល់កន្លែងដែលហៅថាភ្នំលលាក្បាលហើយ គេឆ្កាងទ្រង់នៅទីនោះ» (លូកា ២៣:៣៣)។ អំពើបាបរបស់យើងបានឈានដល់ការអាក្រក់ខ្លាំងបំផុតរបស់វានៅឯឈើឆ្កាង ហើយវាត្រូវបានបើកសំដែងនៅឯឈើឆ្កាងផងដែរ។ យើងទាំងអស់គ្នាមិនស្តាប់តាមសេចក្តីបង្គាប់របស់ព្រះ បន្ទាប់មកយើងបានឆ្កាងព្រះរាជបុត្រានៃព្រះ។ការវិនិច្ឆ័យរបស់ព្រះត្រូវតែធ្លាក់មកលើមនុស្សជាតិ ប៉ុន្តែព្រះបានបង្វែរការវិនិច្ឆ័យដែលយើងសមនឹងទទួលទៅកន្លែងមួយផ្សេងទៀត។

នៅពេលពួកទាហ៊ានកំពុងដំព្រះយេស៊ូវភ្ជាប់នឹងឈើឆ្កាង ព្រះអម្ចាស់របស់យើងបានអធិស្ឋានថា «ឱព្រះវរបិតាអើយ សូមអត់ទោសដល់អ្នកទាំងនេះផង ដ្បិតគេមិនដឹងជាគេធ្វើអ្វីទេ» (លូកា ២៣:៣៤)។ នៅពេលព្រះយេស៊ូវបានមានបន្ទូលដូចនេះ ទ្រង់លះចោលអង្គទ្រង់នៅក្រោមការវិនិច្ឆ័យរបស់ព្រះ។ ទ្រង់ដឹងថាការវិនិច្ឆ័យនឹងមកដល់នៅថ្ងៃនោះ ហើយវាបានមកមែន។ ប៉ុន្តែទ្រង់បានស្រែកអង្វរទៅកាន់ព្រះវរបិតាថា «សូមកុំឲ្យវាធ្លាក់មកលើពួកគេឡើយ។ សូមឲ្យវាធ្លាក់មកលើទូលបង្គំវិញចុះ»។

នេះគឺជាអ្វីដែលបានកើតឡើងនៅកាល់វ៉ារី។ ការដាក់ទណ្ឌកម្មព្រោះតែអំពើបាបរបស់អ្នកត្រូវបានផ្ទុកទៅលើព្រះយេស៊ូវវិញ។ ព្រះជាម្ចាស់អត់ទោសយើងតាមរយៈការរងទុក្ខនិងការសុគត់របស់ទ្រង់នៅលើឈើឆ្កាងជំនួសអ្នក។ បណ្តាសារ

បានធ្លាក់ទៅលើព្រះយេស៊ូវពីព្រោះទ្រង់ «បានផ្ទុកអំពើបាបរបស់យើង» (១ពេត្រុស ២:២៤)។ ទម្ងន់ទោសរបស់យើងបានដាក់លើទ្រង់ (អេសាយ ៥៣:៦) ហើយទ្រង់បានត្រឡប់ជាយញ្ញបូជាសម្រាប់អំពើបាបរបស់យើង។

នៅពេលអំពើបាបរបស់យើងបានឈានដល់ចំនុចកំពូលរបស់វា សេចក្តីស្រលាញ់របស់ព្រះត្រូវបានបង្ហាញដោយសិរីល្អ។ បើសិនអ្នកសង្ស័យអំពីសេចក្តីស្រលាញ់របស់ព្រះសម្រាប់អ្នក សូមមើលទៅឯឈើឆ្កាងចុះ។ គ្មានសេចក្តីស្រលាញ់ណាដែលស្មើនឹងសេចក្តីស្រលាញ់នេះឡើយ។ សេចក្តីស្រលាញ់របស់ព្រះសម្រាប់យើងនៅក្នុងព្រះគ្រីស្ទគឺធំធេងជាងដែលយើងធ្លាប់ស្រម៉ៃទៅទៀត។

## ការរស់ពីសុគតឡើងវិញ

«ទ្រង់មានព្រះជន្មរស់ឡើងវិញហើយ មិនគង់នៅទីនេះទេ» (លូកា ២៤:៦)។ ពេលព្រឹកដែលព្រះអម្ចាស់រស់ពីសុគត់ឡើងវិញ ស្ត្រីមួយក្រុមបានទៅឯផ្នូរដែលគេបានដំកល់សពរបស់ព្រះយេស៊ូវ ហើយពួកគេឃើញថាផ្នូរនៅទទេ។ ដំណឹងល្អដែលពួកគេបានឮគឺមិនមែន «ព្រះយេស៊ូវនៅរស់» ទេ ប៉ុន្តែ «ទ្រង់មានព្រះជន្មរស់ឡើងវិញហើយ»។ ព្រះរាជបុត្រានៃព្រះបាននៅរស់លើស្ថានសួគ៌មុនពេលទ្រង់បានយាងមកយកនិស្ស័យជាមនុស្ស។ ទ្រង់អាចបានត្រឡប់ទៅស្ថានសួគ៌វិញដោយចាកចោលរូបកាយដែលត្រូវជាប់ឆ្កាងទុកនៅក្នុងផ្នូរ។ ពួកទេវតាអាចបាននិយាយថា «សពរបស់ទ្រង់នៅក្នុងផ្នូរប៉ុន្តែសូមកុំខ្លាច
វិញ្ញាណរបស់ទ្រង់គង់នៅជាមួយព្រះវរបិតានៅលើស្ថានសួគ៌»។ ប៉ុន្តែការធ្វើដូចនេះមិនអាចបានបំពេញសម្រេចគោលបំណងប្រោសលោះរបស់ព្រះសម្រាប់យើងបាននោះទេ។

នៅពេលព្រះបានបង្កើតពួកទេវតា ទ្រង់បានបង្កើតពួកគេជាវិញ្ញាណដោយគ្មានរូបកាយ ហើយនៅពេលទ្រង់បានបង្កើតសត្វ ទ្រង់បានបង្កើតពួកវាជារូបកាយដោយគ្មានវិញ្ញាណឬព្រលឹង។ ប៉ុន្តែទ្រង់បានបង្កើតយើងពិសេសដោយឡែកដោយរួមបញ្ចូលរូបកាយនិងវិញ្ញាណជាមួយគ្នា។

សេចក្តីស្លាប់បំបែកអ្វីដែលព្រះបានដាក់បញ្ចូលគ្នា។ វាគឺជាការរំលាយលក្ខណៈរបស់យើងចោល ហើយនេះជាមូលហេតុដែលសេចក្តីស្លាប់គឺជាខ្មាំងសត្រូវដ៏អាក្រក់ដូច្នេះ។ ប៉ុន្តែព្រះគ្រីស្ទបានយាងកាត់សេចក្តីស្លាប់ បានឈ្នះលើសេចក្តីស្លាប់ ហើយបានយាងចេញពីសេចក្តីស្លាប់។ ទ្រង់បានយាងមកដើម្បីប្រោសលោះជីវិត(ព្រលឹង និងរូបកាយ) របស់អ្នក ហើយដាក់អ្នករាល់គ្នាទៅចំពោះព្រះវរបិតាដោយឥតមានកន្លែងបន្ទោសបាន ព្រមទាំងមានចិត្តត្រេកអរផង (យូដាស ២៤)។

បន្ទាប់មកព្រះគ្រីស្ទបានបើកគំនិតរបស់ពួកសិស្សដើម្បីឲ្យពួកគេអាចមើលឃើញថា ព្រះរាជសារទាំងស្រុងរបស់ព្រះគម្ពីរនាំទៅដល់ និងហូរចេញពីការសុគតនិងការរស់ឡើងវិញរបស់ទ្រង់។ ទ្រង់បានប្រាប់ពួកគេថា «ព្រះគ្រីស្ទត្រូវរងទុក្ខលំបាក ហើយនៅថ្ងៃទីបីទ្រង់នឹងរស់ពីស្លាប់ឡើងវិញ ហើយត្រូវឲ្យការប្រែចិត្តនិងសេចក្តីប្រោសឲ្យរួច បានប្រកាសប្រាប់អស់ទាំងសាសន៍ ដោយនូវព្រះនាមទ្រង់» (លូកា ២៤:៤៥-៤៧)។

ព្រះគ្រីស្ទមានភាពច្បាស់លាស់នឹងព្រះរាជសារដែលពួកសាវ័កត្រូវតែប្រកាសៈ ការប្រែចិត្ត និងសេចក្តីអត់ទោសបាប។ ការប្រែចិត្តមានន័យថា អ្នកផ្លាស់ប្តូរគំនិតរបស់អ្នកទាំងស្រុងពីអំពើបាបរបស់អ្នក ហើយតម្រង់ឥរិយាបថទាំងមូលឆ្ពោះទៅកាន់ព្រះយេស៊ូវគ្រីស្ទ។ អ្នកផ្តាច់ខ្លួនចេញពីការបដិសេធរបស់លោកិយចំពោះព្រះយេស៊ូវ ហើយអ្នកឈរជាមួយទ្រង់ដោយទុកចិត្តលើសេចក្តីមេត្តាករុណារបស់ទ្រង់ និងដាក់ខ្លួនរបស់អ្នកនៅក្រោមអំណាចរបស់ទ្រង់។

សេចក្តីអត់ទោសមានន័យថា ព្រះយេស៊ូវអោបក្រសោបអ្នកនៅក្នុងសេចក្តីស្រលាញ់។ ទ្រង់សំអាតទោសកំហុសរបស់អ្នក ផ្សះផ្សារអ្នកនឹងព្រះវរបិតា ហើយចូលមកក្នុងជីវិតរបស់អ្នកតាមរយៈព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់ ហើយប្រទានអំណាចឲ្យអ្នករស់នៅក្នុងជីវិតថ្មីដែលពោរពេញដោយសេចក្តីជំនឿនិងសេចក្តីស្តាប់បង្គាប់ដែលទ្រង់ហៅអ្នកមកនោះ។

## ការលើកឡើងទៅស្ថានសួគ៌របស់ព្រះយេស៊ូវ

«រួចទ្រង់បានលើកព្រះហស្តឡើងប្រទានពរឲ្យ។ កំពុងដែលទ្រង់ប្រទានពរ នោះព្រះវរបិតាបានញែកទ្រង់ចេញពីគេ លើកឡើងទៅស្ថានសួគ៌ទៅ» (លូកា ២៤:៥០-៥១)។ ការមើលឃើញចុងក្រោយរបស់ពួកសិស្សទៅលើព្រះយេស៊ូវគឺឃើញទ្រង់បានលើកព្រហស្តឡើងប្រទានពរពួកគេ។ ការងារធួននឹងបាបនៅលើឈើឆ្កាងរបស់ព្រះគ្រីស្ទត្រូវបានរួចជាស្រេច។ ប៉ុន្តែការងារប្រទានពរដល់ពួកសិស្សបានបន្តសូម្បីតែទ្រង់បានយាងទៅស្ថានសួគ៌វិញក៏ដោយ។ សេចក្តីពិតដ៏អស្ចារ្យនេះត្រូវតែដក់ជាប់នៅក្នុងចិត្តនិងគំនិតរបស់ពួកសិស្សតាមរយៈការលើកឡើងទៅលើស្ថានសួគ៌របស់ព្រះគ្រីស្ទ។

សព្វថ្ងៃនេះនៅខាងស្តាំព្រះហស្តរបស់ព្រះវរបិតា ព្រះគ្រីស្ទបន្តប្រទានពរដល់មនុស្ស។ ព្រះហស្តរបស់ទ្រង់មិនលើកប្រឆាំងទាស់នឹងយើងនោះទេ ប៉ុន្តែព្រះអង្គជាអ្នកទូលអង្វរជំនួសយើងវិញ។ ទ្រង់មិនមានបន្ទូលកាត់ទោសមកកាន់យើងនោះទេ ប៉ុន្តែអំពីព្រះពរវិញ។ ព្រះបន្ទូលរបស់ទ្រង់គឺជាជីវិត។ នៅពេលអ្នក «នៅក្នុងព្រះគ្រីស្ទ» គ្រប់យ៉ាងដែលជារបស់ទ្រង់ក្លាយទៅជារបស់អ្នក។ ការសុគតរបស់ទ្រង់ដើម្បីផ្ទុកអំពើបាបគឺជារបស់អ្នក ជីវិតរស់ពីការសុគត់របស់ទ្រង់គឺជារបស់អ្នក ហើយថ្ងៃមួយអ្នកនឹងត្រឡប់ជាអ្នករួមចំណែកក្នុងការលើកឡើងទៅលើស្ថានសួគ៌វិញរបស់ទ្រង់ផងដែរ។

> ព្រះអម្ចាស់ទ្រង់នឹងយាងចុះពីស្ថានសួគ៌មក ដោយស្រែកបង្គាប់មួយព្រះឱស្ឋ ទាំងមានឮសម្លេងមហាទេវតា និងត្រែរបស់ព្រះផង នោះពួកស្លាប់ក្នុងព្រះគ្រីស្ទនឹងរស់ឡើងវិញជាមុនបង្អស់ (ពួកអ្នកជឿដែលបានឆ្លងកាត់សេចក្តីស្លាប់មកឯវត្តមានរបស់ព្រះយេស៊ូវ) រួចយើងរាល់គ្នាដែលកំពុងតែរស់នៅ ក៏នឹងបានលើកឡើងទៅក្នុងពពកជាមួយគ្នាទាំងអស់ ដើម្បីឲ្យបានជួបជុំជាមួយព្រះអម្ចាស់នៅនាអាកាស។ (១ថែស្សាឡូនិច ៤:១៦-១៧)។

នៅពេលព្រះគ្រីស្ទយាងមកក្នុងសិរីល្អ ប្រជារាស្ត្រទាំងអស់របស់ទ្រង់នឹងមានចំណែកក្នុងការលើកឡើងទៅលើស្ថានសួគ៌របស់ទ្រង់។ រូបកាយរបស់អស់អ្នកដែលបានស្លាប់នឹងបានប្រោសឲ្យរស់ឡើងវិញ ហើយប្រជារាស្ត្ររបស់ព្រះដែលបានប្រោសលោះក្នុងព្រះគ្រីស្ទ នឹងនៅជាមួយទ្រង់អស់កល្បជានិច្ច។

## ការសន្និដ្ឋាន

នេះគឺជាអ្វីដែលព្រះសន្យានឹងយើងនៅក្នុងព្រះគ្រីស្ទ។ ព្រះយេស៊ូវបានយាងមក ហើយបានរស់នៅ ហើយបានសុគតដើម្បី:

១. យើងក្លាយជាស្នាព្រះហស្តថ្មីដែលមានរូបភាពនៃព្រះយ៉ាងពេញលេញ។

២. យើងត្រូវបានសង្គ្រោះចេញពីបណ្តាសាររបស់ការអាក្រក់។

៣. យើងរីករាយនឹងព្រះពររបស់ព្រះជាមួយនឹងក្រុមមនុស្សដែលបានប្រោសលោះដ៏ធំពីគ្រប់ជាតិសាសន៍។

៤. យើងត្រូវបានផ្សះផ្សារនឹងព្រះតាមរយៈព្រះគ្រីស្ទដែលបានប្រទានអង្គទ្រង់ជាយញ្ញបូជាសម្រាប់អំពើបាបរបស់យើង។

៥. យើងរស់នៅក្រោមព្រះពរនៃការគ្រប់គ្រងរបស់ព្រះអស់កល្បជានិច្ច។

៦. យើងដើរក្នុងផ្លូវរបស់ព្រះ ស្រលាញ់ទ្រង់ដោយអស់ពីចិត្ត ហើយស្រលាញ់អ្នកជិតខាងរបស់យើងដូចជាខ្លួនឯង។

៧. យើងទទួលបានជីវិតថ្មីចេញពីផ្នូរ។

ព្រះបោះត្រាលើសេចក្តីសន្យាទាំងអស់របស់ទ្រង់ដោយពាក្យថា «បាទ» នៅក្នុងព្រះយេស៊ូវ (២កូរិនថូស ១:២០)។ ព្រះយេស៊ូវគឺជាភ្លើងខៀវសម្រាប់សេចក្តីសន្យាទាំងអស់របស់ព្រះ ហើយអ្នកអាចមានទំនុកចិត្តទាំងស្រុងថា គ្រប់យ៉ាងដែលព្រះបានសន្យាគឺជារបស់អ្នកនៅក្នុងទ្រង់។

បន្ទាប់មកទៀត យើងងាកទៅកណ្ឌសំបុត្រក្នុងព្រះគម្ពីរសញ្ញាថ្មីម្តងដែលយើងមើលឃើញអំពីរបៀបដែលព្រះ វិញ្ញាណបរិសុទ្ធអនុវត្តគ្រប់ការទាំងអស់ដែលព្រះគ្រីស្ទបានសម្រេចនៅក្នុងជីវិតរបស់រាស្ត្ររបស់ទ្រង់។

## *ពួកជំនុំប្រកាសសេចក្ដីសន្យា: រឿងនៅក្នុងកណ្ឌកិច្ចការ*

មុនពេលព្រះយេស៊ូវបានយាងទៅស្ថានសួគ៌វិញ ទ្រង់បានសន្យានឹងបញ្ជូនព្រះវិញ្ញាណបរិសុទ្ធមកកាន់ពួកសិស្ស។ ព្រះគ្រីស្ទនឹងយាងត្រឡប់ទៅព្រះវរបិតានៅលើស្ថានសួគ៌ ប៉ុន្តែវត្តមាននិងអំណាចរបស់ទ្រង់នៅជាមួយពួកគេដោយព្រះវិញ្ញាណបរិសុទ្ធ។ សេចក្ដីសន្យារបស់ព្រះគ្រីស្ទត្រូវបានបំពេញសម្រេចនៅថ្ងៃបុណ្យទី៥០។ ពេត្រុសបាននិយាយទៅកាន់ហ្វូងមនុស្សដ៏ធំពីគ្រប់ជាតិសាសន៍ដែលបានប្រជុំគ្នាក្នុងយេរូសាឡឹម។ គាត់បានពណ៌នាអំពីជីវិត ការសុគត និងការរស់ឡើងវិញពីសុគតរបស់ព្រះយេស៊ូវ ហើយបន្ទាប់មកគាត់បានពេញដោយព្រះវិញ្ញាណបរិសុទ្ធ ហើយគាត់ប្រកាសថា «ព្រះទ្រង់បានលើកព្រះយេស៊ូវនេះ ដែលអ្នករាល់គ្នាបានឆ្កាង ឲ្យទ្រង់ធ្វើជាព្រះអម្ចាស់ហើយជាព្រះគ្រីស្ទផង» (កិច្ចការ ២:៣៦)។

មនុស្សបានជឿយ៉ាងច្បាស់លើអ្វីដែលពេត្រុសកំពុងប្រាប់ពួកគេ។ បើសិនពួកគេអត់ជឿ ពួកគេបានជជែកប្រឆាំងឬបានដើរចេញទៅ។ ប៉ុន្តែនោះមិនមែនជាប្រត្តិកម្មរបស់ពួកគេទេ។ «កាលគេបានឮ (សាររបស់ពេត្រុសអំពីព្រះយេស៊ូវ) នោះគេមានសេចក្ដីចាក់ចុចក្នុងចិត្ត ក៏សួរពេត្រុសនិងពួកសាវ័កដទៃទៀតថា «បងប្អូនអើយ តើយើងខ្ញុំត្រូវធ្វើដូចម្ដេច?» (កិច្ចការ ២:៣៧)។

ពេត្រុសបានឆ្លើយតបថា «ចូរអ្នករាល់គ្នាប្រែចិត្តចុះ» (កិច្ចការ ២:៣៨)។ ការនេះសំខាន់។ សេចក្ដីជំនឿពិតរួមបញ្ចូលទាំងការប្រែចិត្ត ហើយការប្រែចិត្តពិតរួមបញ្ចូលទាំងសេចក្ដីជំនឿ។ សេចក្ដីជំនឿនិងការប្រែចិត្តគឺដូចជាជ្រុងទាំងពីររបស់កាក់មួយ គឺអ្នកមិនអាចមានមួយដោយគ្មានមួយទៀតនោះទេ។ សេចក្ដីជំនឿនិងការប្រែចិត្តចាប់ផ្ដើមជាមួយគ្នានៅពេលអ្នកមើលឃើញសេចក្ដីស្រលាញ់និងសេចក្ដីមេត្តាករុណារបស់ព្រះសម្រាប់អ្នកនៅក្នុងព្រះយេស៊ូវគ្រីស្ទ។

ពេត្រុសបានបន្តថា «ចូរអ្នករាល់គ្នាប្រែចិត្តចុះ ហើយទទួលបុណ្យជ្រមុជទឹកទាំងអស់គ្នា ដោយនូវព្រះនាមព្រះយេស៊ូវគ្រីស្ទ» (កិច្ចការ ២:៣៨)។ ពេត្រុសប្រាប់ពួកគេឲ្យទទួលព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទជាសាធារណៈ ហើយទទួលការចំណាំសញ្ញា និងត្រារបស់សេចក្ដីសន្យារបស់ព្រះ។ ព្រះសន្យាប្រទានការអត់ទោសអំពើបាបនិងអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធដល់អស់អ្នកដែលទ្រង់ហៅ (កិច្ចការ ២:៣៨-៣៩)។ ព្រះនឹងអត់ទោសឲ្យអ្នក។ ទ្រង់នឹងផ្សះផ្សារអ្នកនឹងអង្គទ្រង់។ ព្រះគ្រីស្ទនឹងប្រទានឲ្យអ្នកនូវជីវិតថ្មីដោយព្រះវិញ្ញាណបរិសុទ្ធដែលទ្រង់នឹងប្រទានឲ្យអ្នក។

យើងគួរតែចងចាំថា ពេត្រុសកំពុងនិយាយនៅក្នុងទីក្រុងតែមួយដែលជាកន្លែងព្រះយេស៊ូវត្រូវបានគេឆ្កាងកាលហាសិបថ្ងៃមុននេះទេ។ អ្នកខ្លះដែលនៅទីនោះក្នុងថ្ងៃបុណ្យទី៥០ គឺបាននៅក្នុងចំណោមហ្វូងមនុស្សដែលបានស្រែកឲ្យគេឆ្កាងទ្រង់ បានយំថា «ចូរឲ្យឈាមវាធ្លាក់មកលើយើងរាល់គ្នា និងកូនចៅរបស់យើងចុះ» (ម៉ាថាយ ២៧:២៥)។ ពេត្រុសនិយាយអំពីការអត់ទោសនិងអំណោយទាននៃព្រះវិញ្ញាណទៅកាន់មនុស្សទាំងនេះថា «ដ្បិតសេចក្ដីសន្យានោះ គឺសន្យាដល់អ្នករាល់គ្នា និងកូនចៅអ្នករាល់គ្នា ព្រមទាំងអស់អ្នកដែលនៅឆ្ងាយដែរ គឺដល់អស់អ្នកណាដែលព្រះអម្ចាស់ជាព្រះនៃយើងរាល់គ្នាទ្រង់នឹងហៅ» (កិច្ចការ ២:៣៩)។

សេចក្ដីសន្យាគឺសម្រាប់ «អ្នក»។ បើសិនអ្នកជឿលើព្រះ អម្ចាស់យេស៊ូវគ្រីស្ទហើយងាកចេញពីអំពើបាបរបស់អ្នក នោះព្រះនឹងអត់ទោសគ្រប់ការទាំងអស់ដែលអ្នកបានធ្វើ។ ទ្រង់នឹងប្រទានព្រះវិញ្ញាណបរិសុទ្ធដល់អ្នក ជួយអ្នកឲ្យមានសេរីភាពពីផ្លូវចាស់ ហើយរស់នៅជាជីវិតថ្មីវិញ។

សេចក្ដីសន្យាគឺសម្រាប់ «កូនចៅរបស់អ្នក»។ នេះមានន័យថា វាមិនកំណត់តែមនុស្សមួយជំនាន់ដែលបានរស់នៅកាលពីពីរពាន់ឆ្នាំកន្លងទៅនោះទេ។ វាមិនត្រូវជាប់គាំងក្នុងអតីតកាលនោះទេ។ សេចក្ដីសន្យានេះមិនចេះហួសសម័យនោះឡើយ។ វាឆ្លងកាត់ជាច្រើនសតវត្ស ហើយវាគឺសម្រាប់យើងនៅថ្ងៃនេះ។

សេចក្តីសន្យាគឺសម្រាប់អស់អ្នកដែលនៅ «ឆ្ងាយ»។ សេចក្តីសន្យាឲ្យបានទទួលការអត់ទោសនិងជីវិតថ្មីក្នុងព្រះយេស៊ូវគ្រីស្ទគឺសម្រាប់មនុស្សមកពីប្រវត្តិខុសៗគ្នា។ បើសិនអ្នកមានអារម្មណ៍ថាឆ្ងាយពីព្រះនៅថ្ងៃនេះ នោះសេចក្តីសន្យានេះគឺសម្រាប់អ្នកហើយ។

ព្រះបានសន្យាថា តាមរយៈពូជរបស់អ័ប្រាហាំ មនុស្សគ្រប់ជាតិសាសន៍នៅលើផែនដីនឹងបានព្រះពរ។ ការអត់ទោសនិងជីវិតថ្មីក្នុងព្រះយេស៊ូវគ្រីស្ទគឺជាសេចក្តីសន្យារបស់ព្រះ សម្រាប់មនុស្សមកពី អាហ្វ្រិក អាស៊ី អាមេរិក អឺរ៉ុប អូស្ត្រាលី និងអង់តាកទិច។ បេសកកម្មរបស់ពួកជំនុំគឺត្រូវតែយកដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទនេះទៅកាន់មនុស្សគ្រប់គ្នា។

សេចក្តីសន្យាគឺ សម្រាប់«អស់អ្នកណាដែលព្រះអម្ចាស់ទ្រង់នឹងហៅ»។ ទ្រង់ហៅតាមរយៈដំណឹងល្អ។ ព្រះបានកំពុងហៅមនុស្សទាំងនោះដែលនៅទីនោះ នៅពេលពេត្រុសកំពុងនិយាយអំពីព្រះគ្រីស្ទ។ ព្រះកំពុងហៅអ្នកនៅថ្ងៃនេះ នៅពេលអ្នកអានដំណឹងល្អ។ មានការអត់ទោសនិងជីវិតថ្មីសម្រាប់អ្នកនៅក្នុងព្រះយេស៊ូវគ្រីស្ទនៅថ្ងៃនេះ។

## *ព្រះវិញ្ញាណបរិសុទ្ធប្រទានសេចក្តីសន្យាៈ រឿងក្នុងកណ្ឌសំបុត្រក្នុងព្រះគម្ពីរសញ្ញាថ្មី*

តើជីវិតថ្មីក្នុងព្រះគ្រីស្ទនេះដូចជាអ្វី? តើមានអ្វីកើតឡើងនៅពេលព្រះវិញ្ញាណបរិសុទ្ធប្រទានសេចក្តីសន្យារបស់ព្រះនៅក្នុងមនុស្សម្នាក់ដែលប្រែចិត្តជឿ? តើអ្វីដែលព្រះបានធ្វើសម្រាប់អ្នកនិងក្នុងអ្នកតាមរយៈព្រះយេស៊ូវគ្រីស្ទ?

កណ្ឌសំបុត្រក្នុងព្រះគម្ពីរសញ្ញាថ្មីនាំយើងចូលក្នុងសេចក្តីសន្យារបស់ព្រះដើម្បីបង្ហាញយើងអំពីគ្រប់យ៉ាងដែលជារបស់យើងក្នុងព្រះយេស៊ូវគ្រីស្ទ។ ខ្ញុំចង់ឲ្យអ្នកមើលឃើញគ្រប់ការងារប្រោសលោះទាំងអស់របស់ព្រះនៅក្នុងជិវិតរបស់មនុស្សម្នាក់។ វាចាប់ផ្តើមដោយការកែជាថ្មីឡើងវិញ។

### ការកែជាថ្មីឡើងវិញៈ អ្នកមានជីវិតថ្មី

«សូមសរសើរដល់ព្រះដ៏ជាព្រះវរបិតានៃព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់នៃយើងរាល់គ្នាដែលទ្រង់បានបង្កើតយើងឡើងជាថ្មីតាមសេចក្តីមេត្តាករុណាដ៏ធំរបស់ទ្រង់ដើម្បីឱ្យយើងរាល់គ្នាបានសេចក្តីសង្ឃឹមដ៏រស់ដោយសារព្រះយេស៊ូវគ្រីស្ទទ្រង់រស់ពីស្លាប់ឡើងវិញ...ដ្បិតព្រះបានបង្កើតអ្នករាល់គ្នាជាថ្មីមិនមែនពីពូជដែលតែងតែពុករលួយនោះទេគឺពីពូជដែលមិនចេះពុករលួយវិញគឺជាព្រះបន្ទូលដ៏រស់ហើយនៅជាប់លាប់ » (១ពេត្រុស១:៣,២៣)។

នៅពេលព្រះបានបង្កើតផ្ទៃមេឃនិងផែនដី ភពរបស់យើងខូចហើយនៅទទេ មានសុទ្ធងងឹតគ្របលើជម្រៅទឹក។ ព្រះវិញ្ញាណរបស់ព្រះបានរេរានៅលើផ្ទៃទឹក (លោកុប្បត្តិ ១:២) បន្ទាប់មកព្រះបានមានបន្ទូលឲ្យមានពន្លឺក្នុងភាពងងឹត ហើយបាននាំឲ្យមានជីវិតនៅក្នុងពិភពលោក។ ព្រះបានបង្កើតសោភ័ណ្ឌភាពរបស់ផែនដី។ ព្រះវិញ្ញាណដដែលដែលបានរេរាលើផ្ទៃទឹកនៅពេលការបង្កបង្កើតគឺដូចជាខ្យល់ផ្លុំចូលទៅក្នុងជីវិតរបស់មនុស្ស (យ៉ូហាន ៣:៨)។ ទ្រង់ប្រទានពន្លឺដល់មនុស្សដែលមិនអាចមើលឃើញសិរីល្អរបស់ព្រះគ្រីស្ទ (២កូរិនថូស ៤:៤) ហើយទ្រង់នាំជីវិតថ្មីដល់មនុស្សដែលស្លាប់ខាងឯព្រះ (អេភេសូរ ២:១)។

ព្រះយេស៊ូវមានបន្ទូលថាព្រះវិញ្ញាណបង្កើតវិញ្ញាណ (យ៉ូហាន ៣:៦)។ នៅពេលព្រះវិញ្ញាណបរិសុទ្ធកែអ្នកឡើងជាថ្មីនោះទ្រង់កែប្រែព្រលឹងរបស់អ្នកដើម្បីឲ្យអ្នកស្រលាញ់ព្រះគ្រីស្ទ ទុកចិត្ត និងដើរតាមទ្រង់ដោយសេរី ដោយគំនិតនិងចិត្តថ្មី។ ព្រះយេស៊ូវពិពណ៌នាការអស្ចារ្យនេះថា «បានកើតជាថ្មី» ឬ «បានកើតពីព្រះវិញ្ញាណ» (យ៉ូហាន ៣:៧-៨)។ ពីខាងក្រោយការជឿទាំងអស់មានព្រះគុណដ៏អស្ចារ្យដែលកែយើងជាថ្មីឡើងវិញ។

ការកែជាថ្មីឡើងវិញនិងសេចក្តីជំនឿគួរតែនាំអ្នកឲ្យថ្វាយបង្គំ។ កូនព្រះត្រូវបានគេស្គាល់និងប្លែកពីគេដោយសេចក្តីជំនឿនៅក្នុងព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ «អស់អ្នកណាដែលទទួលទ្រង់ គឺអស់អ្នកណាដែលជឿដល់ព្រះនាមទ្រង់ នោះទ្រង់បានប្រទានអំណាច ឲ្យបានត្រឡប់ជាកូនព្រះ» (យ៉ូហាន ១:១២)។

តើហេតុអ្វីអ្នកបានជឿប៉ុន្តែអ្នកដទៃមិនបានជឿទៅវិញ? ព្រះ(មិនមែនអ្នក)ផ្តើមការកែអ្នកជាថ្មីឡើងវិញ។ ព្រះបានបើកភ្នែករបស់អ្នកឲ្យមើលឃើញសិរីល្អរបស់ព្រះគ្រីស្ទ។ ព្រះវិញ្ញាណបរិសុទ្ធបានរេរាលើភាពងងឹតនៃជីវិតរបស់អ្នក ហើយបានធ្វើឲ្យអ្នកក្លាយជាស្នាព្រះហស្តថ្មីនៅក្នុងព្រះគ្រីស្ទ។

តើអ្នកមើលឃើញថា ព្រះបានធ្វើការអស្ចារ្យនៅក្នុងព្រលឹងរបស់អ្នកគឺបានប្រទានជិវិតថ្មីពីស្ថានលើដល់អ្នកដែរឬទេ? ព្រះបានប្រទានចិត្តថ្មីដល់អ្នក។ ទ្រង់បានដាក់វិញ្ញាណរបស់ទ្រង់ក្នុងអ្នក។ ទ្រង់បានប្រទានឲ្យអ្នកនូវកំណើតថ្មីនៅក្នុងសេចក្តីសង្ឃឹមដ៏រស់តាមរយៈការរស់ពីសុគត់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ (១ពេត្រុស ១:៣)។

## ការរួបរួមៈ អ្នកនៅក្នុងព្រះគ្រីស្ទ

«តើអ្នករាល់គ្នាមិនដឹងទេឬអីថាយើងទាំងប៉ុន្មានដែលបានទទួលបុណ្យជ្រមុជក្នុងព្រះយេស៊ូវគ្រីស្ទនោះគឺបានទទួលជ្រមុជក្នុងសេចក្តីសុគតនៃទ្រង់ដែរ? ដូច្នេះយើងបានត្រូវកប់ជាមួយនឹងទ្រង់ហើយដោយទទួលជ្រមុជក្នុងសេចក្តីស្លាប់ដើម្បីឱ្យយើងបានដើរក្នុងជីវិតបែបថ្មីដូចជាព្រះគ្រីស្ទបានរស់ពីស្លាប់ឡើងវិញដោយសារសិរីល្អនៃព្រះវរបិតាដែរ។» (រ៉ូម ៦:៣-៤)។

នៅពេលខ្ញុំធ្វើបុណ្យជ្រមុជទឹកឲ្យគេ ខ្ញុំពន្លិចពួកគេចុះទៅក្នុងទឹក។ នៅពេលព្រះគ្រីស្ទបានធ្វើពិធីជ្រមុជឲ្យមនុស្សម្នាក់ដោយព្រះវិញ្ញាណបរិសុទ្ធ អ្នកនោះត្រូវបានពន្លិច «ទៅក្នុងព្រះវិញ្ញាណ» ដូច្នេះហើយអ្នកនោះត្រូវបានរួបរួមជាមួយនឹងព្រះគ្រីស្ទ។ ការរួបរួមជាមួយនឹងព្រះគ្រីស្ទនេះគឺជាសេចក្តីពិតដ៏អស្ចារ្យដែលពិធីបុណ្យជ្រមុជទឹកចង្អុលទៅកាន់។ តាមព្រះគម្ពីរសញ្ញាថ្មី លោក ម៉ាទីន លូធឺ ពិពណ៌នាអំពីការរួបរួមរបស់គ្រីស្ទបរិសស័ទជាមួយនឹងព្រះគ្រីស្ទដោយការប្រើរឿងអំពីអាពាហ៍ពិពាហ៍ៈ

> សេចក្តីជំនឿ...រួបរួមព្រលឹងជាមួយនឹងព្រះគ្រីស្ទដូចជាកូនក្រមុំរួបរួមជាមួយនឹងកូនកំលោះរបស់នាងដែរ។ តាមរយៈសេចក្តីអាថ៌កំបាំងនេះ ដូចជាសាវ័កបង្រៀនថា ព្រះគ្រីស្ទនិងព្រលឹងត្រឡប់ជាសាច់តែមួយ ហើយបើសិនពួកគេជាសាច់តែមួយហើយមានអាពាហ៍ពិពាហ៍ពិតប្រាកដមួយរវាងពួកគេ...នោះមានន័យថាគ្រប់យ៉ាងដែលពួកគេមាន ពួកគេមាននូវរួមគ្នា...។ ដោយហេតុនោះ ព្រលឹងដែលជឿអាចអួតអំពីសិរីល្អនៅក្នុងអ្វីដែលព្រះគ្រីស្ទមានដូចជាវាជារបស់ព្រលឹងនោះផ្ទាល់ដែរ។[៣]

ខ្ញុំបានកំពុងគិតថ្មីៗនេះអំពីមនុស្សនៅក្នុងពួកជំនុំដែលយើងបានបម្រើក្នុងប្រទេសអង់គ្លេស ហើយការខិតខំតែបន្តិចបន្តួចដែលខ្ញុំបានអ្វីដើម្បីរក្សាទំនាក់ទំនងជាមួយពួកគេ។ ខ្ញុំក៏បានកំពុងគិតអំពីគម្រោងផ្សេងៗទៀតដែលខ្ញុំមានការយឺតយ៉ាវ ហើយខ្ញុំបានកំពុងគិតថាខ្ញុំគឺជាមនុស្សអន់ម្នាក់។ ពេលព្រឹកបន្ទាប់ ប្រពន្ធរបស់ខ្ញុំ ខារិន Karen កំពុងអង្គុយនៅឯតុសរសេរសំបុត្របុណ្យណូអែល។ នាងផ្ញើរប័ណ្ណជាងមួយរយទៅប្រទេសអង់គ្លេស ដែលប័ណ្ណនិមួយៗមានកំណត់ត្រាសរសេរដោយដៃ ហើយនាងចុះហត្ថលេខាលើប័ណ្ណទាំងនោះថា «ពីខារិន និងខូលីន(ខ្ញុំ)»។

ខ្ញុំបានកំពុងគិតអំពីភាពបរាជ័យរបស់ខ្ញុំក្នុងការរក្សាទំនាក់ទំនងជាមួយនឹងមនុស្សទាំងនេះ ប៉ុន្តែតាមពិតខ្ញុំបានសរសេរសំបុត្រទៅកាន់ពួកគេជារៀងរាល់ឆ្នាំអស់រយៈពេលជប់បួនឆ្នាំមុន! ខ្ញុំមិនបានធ្វើការនេះដោយដៃខ្លួនឯងនោះទេ ប៉ុន្តែនៅពេលខ្ញុំដឹងថា ខ្ញុំរួបរួមជាមួយប្រពន្ធរបស់ខ្ញុំ ខ្ញុំមានអំណរដោយព្រោះខ្ញុំមានចំណែកក្នុងអ្វីដែលនាងបានធ្វើ។ សំបុត្រមួយបានផ្ញើរទៅដោយនូវឈ្មោះរបស់ខ្ញុំជារៀងរាល់ឆ្នាំ!

ព្រះគ្រីស្ទបានធ្វើសម្រាប់យើងនូវអ្វីដែលយើងបានបរាជ័យធ្វើសម្រាប់ខ្លួនឯង។ ទ្រង់មានជីវិតបរិសុទ្ធដែលយើងមិនបានរស់នៅហើយមិនមានសមត្ថភាពរស់នៅ។ ប៉ុន្តែនៅពេលយើង «នៅក្នុងព្រះគ្រីស្ទ» គ្រប់ទាំងអស់ដែលទ្រង់បានធ្វើគឺជារបស់យើង ជីវិត ការសុគត់ និងការរស់ពីសុគត់របស់ទ្រង់ មានឈ្មោះរបស់យើងនៅពីលើដូចជាទាំងអស់នោះជារបស់យើងផ្ទាល់ដែរ។

ការរួបរួមជាមួយព្រះគ្រីស្ទមានន័យថាទ្រង់ត្រូវគេវាយភ្ជាប់ទៅនឹងឈើឆ្កាង ហើយយើងបានរាប់ជាសុចរិត។

## ការរាប់ជាសុចរិត

«ដូច្នេះដែលយើងរាល់គ្នាបានរាប់ជាសុចរិតដោយការជឿនោះឈ្មោះថាយើងបានមេត្រីនឹងព្រះដោយសារព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់នៃយើងរាល់គ្នាហើយ» (រ៉ូម ៥:១)។«បានរាប់ជាសុចរិត» គឺជាពាក្យតាមផ្លូវច្បាប់ដែលពិពណ៌នាអំពីសាលក្រមមួយ។ នៅពេលព្រះរាប់មនុស្សម្នាក់ជាសុចរិត ទ្រង់ប្រកាសថាអ្នកនោះសុចរិត។ នៅពេលទ្រង់កាត់ទោស ទ្រង់ប្រកាសថាមនុស្សម្នាក់មានទោស។ ការរាប់ជាសុចរិតនិងការកាត់ទោសគឺអំពីការទទួលស្គាល់អ្វីមួយដែលពិតប្រាកដហើយ។

នៅពេលយុត្តិធម៌ឈ្នះ មនុស្សមានទោសនឹងត្រូវបានគេកាត់ទោស ហើយមនុស្សឥតទោសនឹងត្រូវបានគេដោះលែង។ ការត្រូវបានដោះលែងមិនធ្វើឲ្យមនុស្សម្នាក់ឥតមានទោសនោះទេ វាជាភាពឥតទោសរបស់មនុស្សទេដែលនាំឲ្យមានការដោះលែង។ ក្នុងរបៀបដូចគ្នា ការត្រូវកាត់ទោសមិនធ្វើឲ្យមនុស្សម្នាក់ក្លាយជាឧក្រិដ្ឋជននោះទេ វាគឺជាទោសឧក្រិដ្ឋរបស់មនុស្សទេដែលនាំឲ្យមានការកាត់ទោស។

សម្រាប់យុត្តិធម៌ យើងគួរតែរំពឹងឲ្យព្រះកាត់ទោសពួកមនុស្សមានបាប ហើយរាប់មនុស្សសុចរិតជាសុចរិត។ ប៉ុន្តែទីនេះមានការមួយដែលពិតជាអស្ចារ្យៈ ព្រះរាប់ពួកមនុស្សមានបាបជាសុចរិត។ ចូរទុកឲ្យការផ្ទុយគ្នាដ៏ធំនេះចូលជ្រៅទៅក្នុងគំនិតរបស់អ្នកចុះ។ ព្រះរាប់ពួកមនុស្សមានបាបជាសុចរិត! តើទ្រង់អាចធ្វើយ៉ាងនោះដោយរបៀបណា?

ព្រះបានប្រទានព្រះយេស៊ូវជាការថ្វាយដង្វាយឲ្យរួចពី សេចក្តីក្រោធសម្រាប់អំពើបាបរបស់យើង (រ៉ូម ៣:២៥)។ នោះមានន័យថា នៅពេលព្រះយេស៊ូវបានសុគត សេចក្តីក្រោធនិងភាពជាខ្មាំងសត្រូវទាំងអស់ដែលព្រះមានចំពោះ អំពើបាប សេចក្តីអាក្រក់ និងការអាក្រក់ត្រូវបានផ្ទុកទៅលើទ្រង់។ ដូចជាពែងមួយដែលពេញដោយការវិនិច្ឆ័យរបស់ព្រះ នោះព្រះយេស៊ូវបានផឹកវារហូតដល់អស់។ នៅលើឈើឆ្កាងព្រះគ្រីស្ទបានទទួលយកការវិនិច្ឆ័យរបស់ព្រះដោយសារតែអំពើបាបរបស់យើង។

សេចក្តីជំនឿបង្រួបបង្រួមយើងជាមួយព្រះគ្រីស្ទ ហើយនៅពេលយើង «នៅក្នុងព្រះគ្រីស្ទ» ព្រះរាប់អំពើបាបទាំងអស់របស់យើងជារបស់ទ្រង់ ហើយសេចក្តីសុចរិតទាំងអស់របស់ទ្រង់ជារបស់យើង។ ទ្រង់បានផ្ទុកការកាត់ទោសរបស់យើងហើយយើងបានរាប់ជាសុចរិតនៅក្នុងទ្រង់។ តាមរយៈឈើឆ្កាង ព្រះបានបង្ហាញយុត្តិធម៌របស់ទ្រង់ដូច្នេះហើយព្រះអង្គរាប់អស់អ្នកដែលមានសេចក្តីជំនឿលើព្រះយេស៊ូវជាសុចរិត (រ៉ូម ៣:២៦)។

ប្រសិនបើព្រះរាប់តែមនុស្សសុចរិតជាសុចរិត នោះតើយើងអាចមានសេចក្តីសង្ឃឹមពីណាមក? ដំណឹងល្អគឺថា ព្រះរាប់មនុស្សទុច្ចរិតជាសុចរិត (រ៉ូម ៤:៥)។ ដោយសារសេចក្តីជំនឿបង្រួបបង្រួមយើងជាមួយព្រះយេស៊ូវគ្រីស្ទ នោះអំណាចនៃយញ្ញបូជាធួននឹងបាបរបស់ទ្រង់ត្រឡប់ជារបស់យើងវិញ។ យើងត្រូវបានដោះលែងចេញពីសេចក្តីភ័យខ្លាចនៃការកាត់ទោសអំពើបាបនិងទោសកំហុសរបស់យើង ហើយយើងត្រូវបាននាំមកក្នុងសេចក្តីស្រលាញ់ដ៏អស្ចារ្យ។

## ការទទួលយកជាកូនចិញ្ចឹមៈ ព្រះស្រលាញ់អ្នក

«តែលុះវេលាកំណត់បានមកដល់ នោះព្រះទ្រង់បានចាត់ព្រះរាជបុត្រាទ្រង់ឱ្យមកចាប់កំណើតនឹងស្ត្រី គឺកើតក្រោមអំណាចនៃក្រិត្យវិន័យដើម្បីនឹងលោះពួកអ្នកដែលនៅក្រោមក្រិត្យវិន័យ ប្រយោជន៍ឱ្យយើងបានទទួលសគុណ ទុកជាកូនចិញ្ចឹមហើយដោយព្រោះអ្នករាល់គ្នាជាកូន បានជា ព្រះទ្រង់ចាត់ព្រះវិញ្ញាណនៃព្រះរាជបុត្រាទ្រង់ ឱ្យមកក្នុងចិត្តអ្នករាល់គ្នា ឱ្យបន្លឺឡើងថា អ័ប្បា ព្រះវរបិតាអើយដូច្នេះអ្នករាល់គ្នាមិនមែនជាបាវបំរើទៀតទេ គឺជាកូនវិញ ហើយបើជាកូននោះនឹងបានមរដកនៃព្រះ ដោយសារព្រះគ្រីស្ទដែរ។» (កាឡាទី ៤:៤-៧)។

តាមរយៈព្រះគ្រីស្ទ ព្រះទទួលយកយើងជាកូនចិញ្ចឹមនៅក្នុងគ្រួសាររបស់ទ្រង់ហើយស្រឡាញ់យើងជាកូនប្រុសនិងកូនស្រីរបស់ទ្រង់ផ្ទាល់។ គ្មានបទពិសោធន៍នៃសេចក្តីស្រលាញ់ណាអាចប្រៀបធៀបនឹងសេចក្តីស្រលាញ់ដែលព្រះមានសម្រាប់អ្នកនៅក្នុងព្រះគ្រីស្ទនោះទេ។ មនុស្សម្នាក់ប្រហែលស្បថថានឹងស្រលាញ់យើង «ដរាបណាយើងទាំងពីរនៅរស់»

ប៉ុន្តែព្រះស្បថថានឹងប្រទានសេចក្តីស្រលាញ់របស់ទ្រង់មកក្នុងជីវិតរបស់យើង និងសម្រាប់ភាពអស់កល្បជានិច្ច។ គ្មានអ្នកណាផ្សេងទៀតអាចនិយាយមកកាន់យើងថា «អញនឹងមិនចាកចេញពីឯង ក៏មិនបោះបង់ចោលឯងឡើយ» (ហេព្រើរ១៣:៥)។

ព្រះស្រលាញ់យើងដោយសេចក្តីស្រលាញ់ដ៏នៅ អស់កល្បជានិច្ច។ នោះមានន័យថា ព្រះបានស្រលាញ់យើងនៅមុនយើងបានកើតមក ហើយក៏នៅមុនកំណើតលោកិយទៅទៀត។ ព្រះគ្រីស្ទបានគិតអំពីយើងនៅពេលទ្រង់បានយាងមកក្នុងលោកិយ នៅពេលទ្រង់ត្រូវជាប់ឆ្កាង ហើយនៅពេលទ្រង់បានរស់ពីការសុគត់ឡើងវិញ។

វាគឺជាការងារពិសេសរបស់ព្រះវិញ្ញាណបរិសុទ្ធក្នុងការធ្វើឲ្យយើងជឿថា យើងគឺជាកូនស្ងួនភ្ញាម្នាក់របស់ព្រះ។ «សេចក្តីស្រលាញ់របស់ព្រះបានផ្សាយមកសព្វក្នុងចិត្តយើងរាល់គ្នា ដោយសារព្រះវិញ្ញាណបរិសុទ្ធ ដែលព្រះ បានប្រទានមកយើងហើយ» (រ៉ូម ៥:៥)។ ព្រះវិញ្ញាណធ្វើឲ្យសេចក្តីស្រលាញ់របស់ព្រះពិតប្រាកដនៅក្នុងបទពិសោធន៍របស់យើង។ ទ្រង់ភ្ជាប់យើងទៅនឹងសេចក្តីពិតនៃសេចក្តីស្រលាញ់របស់ព្រះសម្រាប់យើងដែលត្រូវបានបង្ហាញនៅលើឈើឆ្កាង។

រឿងបញ្ហាមួយដែលអ្នកនឹងប្រឈមនៅក្នុងជីវិតជាគ្រីស្ទបរិស័ទគឺ ត្រូវបញ្ឈប់ទំលាប់យកអារម្មណ៍ឬបទពិសោធន៍ឬស្ថានភាពរបស់យើងមកធ្វើជាមូលដ្ឋានគ្រឹះនៃជំនឿរបស់យើងអំពីសេចក្តីស្រឡាញ់របស់ព្រះអង្គ។ សភាវគតិរបស់យើងគឺមានអារម្មណ៍ថា ព្រះស្រលាញ់យើងនៅពេលយើងមានសុខភាពល្អ មានការងារល្អ ហើយជីវិតដំណើរទៅមុខបានល្អប្រសើរ។ ប៉ុន្តែនៅពេលការអាក្រក់កើតឡើងក្នុងជីវិតរបស់យើង សភាវគតិដំបូងរបស់យើងគឺ ត្រូវសង្ស័យអំពីសេចក្តីស្រលាញ់របស់ព្រះ។

អ្វីដែលយើងគួរតែធ្វើគឺ ត្រូវរំលឹកខ្លួនយើងអំពីការសំដែងសេចក្តីស្រលាញ់ដែលវាស់ស្ទង់មិនបានរបស់ព្រះនៅលើឈើឆ្កាង។ «ឯព្រះអង្គដែលមិនបានសំចៃទុកនូវព្រះរាជបុត្រាទ្រង់បង្កើតគឺបានបញ្ជូនទ្រង់ទៅជំនួសយើងរាល់គ្នានោះតើមានទំនងអ្វីឱ្យទ្រង់មិនប្រទានគ្រប់ទាំងអស់មកយើងជាមួយនឹងព្រះរាជបុត្រាទ្រង់នោះផង» (រ៉ូម ៨:៣២)។

## ការញែកជាបរិសុទ្ធៈ អ្នកនឹងបានបរិសុទ្ធ

«សូមឱ្យព្រះនៃសេចក្តីសុខសាន្តញែកអ្នករាល់គ្នាចេញជាបរិសុទ្ធសព្វគ្រប់ហើយឱ្យទាំងព្រលឹងនិងវិញ្ញាណហើយរូបកាយទាំងមូលបានបម្រុងទុកឥតសៅហ្មងដរាបដល់ព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់នៃយើងទ្រង់យាងមកព្រះដែលបានហៅអ្នករាល់គ្នាទ្រង់ស្មោះត្រង់ទ្រង់នឹងធ្វើសម្រេចការនោះ។» (១ថែស្សាឡូនីច ៥:២៣-២៤)។

ព្រះវិញ្ញាណបរិសុទ្ធមានតួនាទីនាំគ្រីស្ទបរិស័ទឲ្យបានរីកចម្រើនក្នុងជីវិតបរិសុទ្ធដែលព្រះហៅឲ្យយើងរស់នៅ។ ដោយសារការងារនេះព្រះវិញ្ញាណបរិសុទ្ធបានញែកយើងជាបរិសុទ្ធ។ វាគឺជាបំណងចិត្តរបស់គ្រីស្ទបរិស័ទ។ អភិបាល រ៉ៃល Ryle និយាយថាៈ

> មនុស្សភាគច្រើនសង្ឃឹមទៅស្ថានសួគ៌នៅពេលពួកគេស្លាប់ ប៉ុន្តែមនុស្សតិចតួចងឿងឆ្ងល់ថា តើពួកគេនឹងរីករាយជាស្ថានសួគ៌បើសិនពួកគេបានទៅដល់ទីនោះឬយ៉ាងណា? ស្ថានសួគ៌គឺជាកន្លែងបរិសុទ្ធ...តើមនុស្សដែលមិនបានញែកជាបរិសុទ្ធអាចធ្វើអ្វីនៅស្ថានសួគ៌បើសិនគាត់បានទៅដល់ទីនោះ?[៤]

យ៉ូហាន អូវិន John Owen បានសរសេរអំពីគំនិតដូចគ្នានេះៈ

> គ្មានគំនិតណាដែលល្ងីល្ងើឬមានគ្រោះថ្នាក់ជាងគំនិតនេះទេ គឺថាមនុស្សម្នាក់ដែលមិនបានញែកជាបរិសុទ្ធ មិនត្រូវបានធ្វើឲ្យបរិសុទ្ធនៅក្នុងជីវិតរបស់គាត់ គួរត្រូវបានយកមកក្នុងព្រះពរដែលមានសេចក្តីរីករាយរបស់ព្រះ(ស្ថានសួគ៌)។មនុស្សបែបនោះមិនអាចរីករាយនឹងព្រះបានទេ ឬក៏ព្រះមិនអាចជារង្វាន់ដល់ពួកគេផងដែរ។ ភាពបរិសុទ្ធនៅស្ថានសួគ៌គឺឥតខ្ចោះ ប៉ុន្តែវាតែងតែត្រូវបានចាប់ផ្តើមនៅក្នុងលោកិយនេះ។[៥]

ការរាប់ជាសុចរិតនិងការញែកជាបរិសុទ្ធតែងតែមានជាមួយគ្នានៅក្នុងព្រះគ្រីស្ទ ហើយរបៀបដែលការទាំងពីរមាន

ទំនាក់ទំនងនឹងគ្នាគឺសំខាន់ណាស់ក្នុងការយល់អំពីដំណឹងល្អ។ កំហុសសាមញ្ញបំផុតពីរគឺការធ្វើឲ្យការទាំងពីរច្រឡំគ្នាឬដាច់ចេញពីគ្នា។ ការច្រឡំកើតឡើងបើសិនអ្នកគិតថា ការឈររបស់អ្នកជាមួយព្រះ(ការដែលព្រះជាម្ចាស់ទទួលអ្នកទៅស្ថានសួគ៌)ពឹងផ្អែកលើជីវិតរបស់អ្នក។ វាមិនពឹងផ្អែកដូច្នោះទេ។ អ្នកត្រូវបានរាប់ជាសុចរិតដោយសារសេចក្តីជំនឿជឿដល់ការងារចប់សព្វគ្រប់របស់ព្រះគ្រីស្ទ។

គំនិតមួយដ៏ខុសគិតថា ដោយសារតែយើងត្រូវបានរាប់ជាសុចរិតដោយសេចក្តីជំនឿតែមួយគត់ នោះយើងមិនចាំបាច់ត្រូវស្តាប់បង្គាប់ព្រះគ្រីស្ទ គឺការស្តាប់បង្គាប់ព្រះគ្រីស្ទមិនសំខាន់នោះទេ។ គំនិតនេះខុសពីព្រោះការស្តាប់បង្គាប់ពិតជាសំខាន់។ ព្រះគ្រីស្ទប្រទានព្រះពរនៃការរាប់ជាសុចរិតនិងការញែកជាសុចរិត។ នៅពេលយើងទទួលព្រះគ្រីស្ទដោយសេចក្តីជំនឿ អំណោយទានទាំងនេះក្លាយជារបស់យើងទាំងអស់។ គ្មានអ្នកណាម្នាក់មានអំណោយទានមួយហើយអត់អំណោយទានមួយទៀតនោះទេ។ នេះជាមូលហេតុដែលព្រះគម្ពីរនិយាយថា «បើអ្នកណាគ្មានសេចក្តីបរិសុទ្ធ នោះមិនដែលឃើញព្រះអម្ចាស់ឡើយ» (ហេព្រើ ១២:១៤)។ នេះមិនមានន័យថា យើងបានសង្គ្រោះដោយភាពបរិសុទ្ធ ប៉ុន្តែមានន័យថាការដេញតាមសេចក្តីបរិសុទ្ធគឺជាភស្តុតាងដែលយើងនៅក្នុងព្រះគ្រីស្ទដែលរាប់យើជាសុចរិតដោយព្រះលោហិតរបស់ទ្រង់។

ប៉ុលអធិស្ឋានឲ្យពួកអ្នកជឿថា «សូមឲ្យព្រះនៃសេចក្តីសុខសាន្ត ញែកអ្នករាល់គ្នាចេញជាបរិសុទ្ធសព្វគ្រប់» ហើយយើងក៏គួរតែអធិស្ឋានថា ព្រះអង្គនឹងញែកយើងជាបរិសុទ្ធផងដែរ។ ប៉ុន្តែការញែកជាបរិសុទ្ធក៏ជាសេចក្តីសន្យាមួយដែរ «ព្រះដែលបានហៅអ្នករាល់គ្នា ទ្រង់ស្មោះត្រង់ ទ្រង់នឹងធ្វើសម្រេចការនោះ» (១ថែស្សាឡូនិច ៥:២៣-២៤)។

ចូរប្រកាន់ខ្ជាប់នូវសេចក្តីសន្យានោះ នៅពេលអ្នកធ្លាក់ទឹកចិត្តដោយកង្វះភាពរីកចម្រើននៅក្នុងជីវិត។ អ្វីដែលព្រះគុណរបស់ព្រះបានចាប់ផ្តើមនៅក្នុងអ្នក នឹងបានសម្រេចសម្រាប់សិរីល្អរបស់ទ្រង់ហើយនិងសម្រាប់អំណររបស់អ្នក។ ព្រះនឹងប្រទានឲ្យអ្នកនូវបំណងចិត្តរបស់អ្នក។ អ្នកនឹងបានត្រឡប់ដូចជារូបអង្គនៃព្រះរាជបុត្រាទ្រង់នៅអស់កល្បជានិច្ច (រ៉ូម ៨:២៩)។

## ការទទួលសិរីល្អ: អ្នកនឹងបញ្ចេញសិរីល្អរបស់ព្រះគ្រីស្ទ

«កាលណាព្រះគ្រីស្ទដ៏ជាជីវិតនៃយើង បានលេចមក នោះអ្នករាល់គ្នានឹងលេចមកក្នុងសិរីល្អជាមួយនឹងទ្រង់ដែរ» (កូល៉ុស ៣:៤)។ ជីវិតរបស់យើងនៅមានការប្រឆាំងគ្នាជាច្រើននៅឡើយ។ នេះគឺជាការពិតសម្រាប់គ្រីស្ទបរិស័ទគ្រប់រូប។ យើងស្រលាញ់ព្រះគ្រីស្ទ ប៉ុន្តែយើងមានអារម្មណ៍ថា លោកិយ សាច់ឈាម និងសាតាំងទាញយើង។ យើងទុកចិត្តព្រះគ្រីស្ទ ប៉ុន្តែយើងតយុទ្ធនឹងការសង្ស័យនិងសេចក្តីភ័យខ្លាចជាច្រើន។ យើងមានជីវិតថ្មីក្នុងព្រះគ្រីស្ទ ប៉ុន្តែក្នុងពេលជាមួយគ្នារូបកាយរបស់យើងនៅក្រោមអំណាចរបស់ជំងឺ ភាពចាស់ និងសេចក្តីស្លាប់។

ពួកគ្រីស្ទបរិស័ទមានការប្រឆាំងគ្នាជាច្រើននៅក្នុងជិវិត ប៉ុន្តែវានឹងមិនតែងតែដូច្នោះទេ។ សេចក្តីស្រលាញ់របស់អ្នកសម្រាប់ព្រះគ្រីស្ទនឹងបានពេញលេញ សេចក្តីជំនឿរបស់អ្នកនឹងត្រូវបានមើលឃើញច្បាស់ ហើយអ្នកនឹងមានអំណរនៃជីវិតអស់កល្បជានិច្ចនៅក្នុងរូបកាយដែលរស់ឡើងវិញ។ អ្នកនឹងនៅជាមួយព្រះគ្រីស្ទក្នុងសិរីល្អអស់កល្បជានិច្ច។

មិនត្រឹមតែអ្នកនឹងនៅក្នុងសិរីល្អរបស់ព្រះគ្រីស្ទទេ តែសិរីល្អរបស់ទ្រង់ក៏នៅក្នុងអ្នកផងដែរ។ ប៉ុលនិយាយថា «ខ្ញុំរាប់អស់ទាំងសេចក្តីទុក្ខលំបាកនៅជាន់នេះ ថាជាសេចក្តីមិនគួរប្រៀបផ្ទឹមនឹងសិរីល្អ ដែលនឹងបើកសំដែងមកឲ្យយើងរាល់គ្នាឃើញនោះទេ» (រ៉ូម ៨:១៨)។ ជីវិតគ្រីស្ទបរិស័ទរបស់អ្នកដូចជាដើមឈើក្នុងរដូវរងារ។ វាមើលទៅដូចជាគ្មានផលផ្លែ ប៉ុន្តែវានៅរស់ ហើយពេលនិទាឃរដូវមកដល់ វានឹងលូតលាស់។ សិរីល្អពេញលេញរបស់វានៅតែត្រូវបានឃើញ។

ការរៀនគិតអំពីសិរីល្អនាពេលអនាគតរបស់អ្នកទុកជាមុនគឺជាគុណប្រយោជន៍ដ៏ធំនៅក្នុងជីវិតគ្រីស្ទបរិស័ទ។ យើងត្រូវតែចងចាំសេចក្តីពិតនេះ នៅពេលវាមើលទៅហាក់ដូចជាគ្រប់យ៉ាងប្រឆាំងនឹងយើង។ លោកប៉ុលបានធ្វើបែបនេះ «ហេតុនោះយើងខ្ញុំមិនណាយចិត្តឡើយ...ដ្បិតសេចក្តីទុក្ខលំបាកយ៉ាងស្រាលរបស់យើងខ្ញុំដែលនៅតែមួយភ្លែតនេះ នោះបង្កើត

ឲ្យយើងខ្ញុំមានសិរីល្អយ៉ាងធ្ងន់លើសលប់ ដ៏នៅអស់កល្បជានិច្ចវិញ (២កូរិនថូស ៤:១៦-១៧)។ សាវ័កប៉ុលកំពុងប្រាប់យើងដោយបទពិសោធន៍ផ្ទាល់ខ្លួនរបស់គាត់អំពីរបៀបធ្វើឲ្យប្រាកដថា យើងមិនណាយចិត្ត។

ព្រះធ្វើការតាមរយៈទុក្ខលំបាកក្នុងជីវិតរបស់អ្នកប្រយោជន៍ដើម្បីយើងឆ្លុះព្រះគ្រីស្ទនៅក្នុងជីវិតរបស់អ្នកដែលនឹងបិតថេរសម្រាប់សិរីល្អរបស់ទ្រង់ និងសម្រាប់អំណររបស់អ្នកនៅអស់កល្បជានិច្ច។ នៅថ្ងៃនោះ យើងនឹងទទួលគ្រប់ទាំងអស់ដែលព្រះសន្យាឲ្យ:

១. យើងនឹងឆ្លុះបញ្ចាំងឲ្យឃើញយើងដូចរូបអង្គទ្រង់យ៉ាងពេញលេញ។

២. យើងត្រូវបានសង្គ្រោះចេញពីការអាក្រក់ដ៏ជាបណ្តាសា។

៣.យើងនឹងមានចំណែកក្នុងអំណរនៃជីវិតអស់កល្បជានិច្ចជាមួយនឹងក្រុមមនុស្សដែលបានប្រោសលោះពីគ្រប់ជាតិសាសន៍។

៤. យើងនឹងចូលទៅក្នុងវត្តមានរបស់ព្រះពីព្រោះព្រះអង្គបានប្រោសលោះយើងដោយព្រះលោហិតរបស់ព្រះយេស៊ូវ។

៥. យើងរស់នៅក្រោមព្រះពរនៃការគ្រប់គ្រងនគររបស់ព្រះអស់កល្បជានិច្ច។

៦. យើងនឹងស្រលាញ់ព្រះដោយអស់ពីចិត្ត ហើយស្រលាញ់អ្នកជិតខាងរបស់យើងដូចជាខ្លួនឯង។

៧. យើងនឹងមានអំណរអស់ល្បជានិច្ចនៅក្នុងជីវិតថ្មីរបស់យើងតាមរយៈព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ។

## ការធ្វើឲ្យពេញលេញ: យើងនឹងជួបព្រះ

«រួចខ្ញុំឃើញផ្ទៃមេឃថ្មីនិងផែនដីថ្មី ដ្បិតផ្ទៃមេឃមុននិងផែនដីមុនបានកន្លងបាត់ទៅហើយ ក៏គ្មានសមុទ្រទៀតឡើយ» (វិវរណៈ ២១:១)។ យ៉ូហានបានឃើញផ្ទៃមេឃថ្មីនិងផែនដីថ្មី មិនមែនផែនដីខុសគ្នាទេ ប៉ុន្តែគឺផែនដីថ្មីមួយ។ ផែនដីនេះជាចុងក្រោយនឹងបានប្រោសលោះចេញពីបណ្តាសា ហើយនឹងបានរំដោះចេញពីចំណងពុករលួយរបស់វា (រ៉ូម ៨:២១)។

បន្ទាប់មកយ៉ូហានបានឃើញ «ទីក្រុងដ៏បរិសុទ្ធ គឺជាក្រុងយេរូសាឡឹមថ្មី ចុះពីស្ថានសួគ៌មកអំពីព្រះ»(វិវរណៈ ២១:២)។ ទីក្រុងនោះមានទ្វារចូលបែរទៅទិសខាងជើង ខាងត្បូង ខាងកើត និងខាងលិច ដែលបង្ហាញថា ព្រះបានបំពេញសម្រេចសេចក្តីសន្យារបស់ទ្រង់ក្នុងការប្រមូលសហគមន៍មនុស្សពីគ្រប់ជាតិសាសន៍នៅលើផែនដី ហើយនាំពួកគេទៅក្នុងអំណរនៃជីវិតនៅក្នុងនគរដ៏អស់កល្បជានិច្ចរបស់ទ្រង់។

រូបភាពតែមួយមិនគ្រប់គ្រាន់ដើម្បីសំដែងសិរីល្អនៃអ្វីដែលព្រះគ្រីស្ទបានរៀបចំសម្រាប់យើងនោះទ្បើយ។ ដូច្នេះ លើសពីទីក្រុងដែលយ៉ូហានបានឃើញរូបភាពកូនក្រមុំតែងខ្លួនយ៉ាងស្អាតសម្រាប់ប្តីរបស់នាងផងដែរ (វិវរណៈ ២១:២)។ ព្រះគ្រីស្ទគឺជាចំនុចកណ្តាលនៃអំណររបស់ស្ថានសួគ៌ ហើយអំណរទាំងអស់របស់យើងនឹងបាននៅក្នុងទ្រង់។

យ៉ូហានបានលឺសំលេងខ្លាំងមួយពីបល្ល័ង្កនៅស្ថានសួគ៌ថា «មើលរោងឧបោសថរបស់ព្រះ បាននៅជាមួយនឹងមនុស្សហើយ ទ្រង់នឹងគង់នៅជាមួយនឹងគេ គេនឹងធ្វើជារាស្ត្ររបស់ទ្រង់ ហើយព្រះអង្គទ្រង់ក៏នឹងធ្វើជាព្រះដល់គេ» (វិវរណៈ ២១:៣)។ គ្រប់យ៉ាងដែលបំបែកយើងចេញពីព្រះបានបាត់អស់ហើយ។ ព្រះចែករំលែកជីវិតអស់កល្បជានិច្ចជាមួយនឹងមនុស្សដែលបានប្រោសលោះរបស់ទ្រង់។ ព្រះនឹងជូតអស់ទាំងទឹកភ្នែកចេញពីភ្នែករបស់អ្នក។ រាស្ត្ររបស់ព្រះនឹងលែងមានទុក្ខលំបាកទៀតហើយ នឹងលែងមានសេចក្តីស្លាប់ ឬសោកសង្រេង ឬសេចក្តីយំទួញ ឬសេចក្តីឈឺចាប់ទៀតហើយ។

## ការសន្និដ្ឋាន

ព្រះបានធ្វើសេចក្តីសន្យាដ៏អស្ចារ្យដែលមានតែព្រះទេដែលអាចប្រទានឲ្យ។ សេចក្តីសន្យាទាំងនោះត្រូវបានបំពេញសំរេចនៅក្នុងព្រះយេស៊ូវគ្រីស្ទ ដែលជាព្រះបន្ទូលបានត្រឡប់ជាសាច់ឈាម។ សេចក្តីសន្យាទាំងនេះរួមមាន ការកែជាថ្មីឡើងវិញ ការរួបរួមជាមួយព្រះគ្រីស្ទ ការរាប់ជាសុចរិត ការទទួលជាកូនចិញ្ចឹម ការញែកជាបរិសុទ្ធ ព្រះអង្គនឹងលើកតម្កើងយើងឡើង ហើយនិងសេចក្តីសន្យាអំពីអំណរដ៏អស់កល្បជានិច្ចនៅក្នុងការធ្វើឲ្យគោលបំណងប្រោសលោះរបស់ព្រះបានពេញលេញ។

សេចក្តីសន្យាទាំងនេះគឺសម្រាប់អស់អ្នកណាដែលនៅក្នុងព្រះយេស៊ូវគ្រីស្ទ។ វាអាចជារបស់អ្នក។ សេចក្តីសន្យាគឺសម្រាប់អ្នករាល់គ្នានិងកូនចៅរបស់អ្នករាល់គ្នា និងសម្រាប់អស់អ្នកដែលនៅឆ្ងាយដែរ។ ចូរប្រែចិត្ត។ ចូរជឿលើព្រះ អម្ចាស់ព្រះយេស៊ូវគ្រីស្ទ។ ដោយសេចក្តីជំនឿ អ្នករាល់គ្នានឹងបានជីវិតដោយសារព្រះនាមទ្រង់ (យ៉ូហាន ២០:៣១)។

## *កំណត់*

១. ខគម្ពីរយោងដែលត្រូវបានដកស្រង់ចេញពីព្រះគម្ពីរខ្មែរបរិសុទ្ធ (១៩៥៤).

២. John Calvin, The Institutes of the Christian Religion, 2.12.3 (http://www.ccel.org/ccel/calvin/institutes.iv.xiii.html).

៣. Martin Luther, “The Freedom of a Christian,” in Martin Luther: Selections from His Writings, ed. John Dillenberger (New York: Anchor, 1962), 60.

៤. J. C. Ryle, Holiness (repr., Chicago: Moody, 2010), 58–59.

៥. Owen’s original wording is cited by Ryle, Holiness, 76–77.